**អង្គការការពារសិទ្ធិជនជាតិភាគតិច**

**Minority Rights Organization**

*(Human Rights Respect, Legal Protection, Peace & Development for Minorities)*

# ឯកសារអត្តសញ្ញាណនិបិតិកជន
# ខេត្តតាកែវ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់
# ២០១៦



## ឧបត្ថម្ភមូលនិធិដោយ

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT
អនុវត្តដោយ: giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

zfd Ziviler Friedensdienst
Civil Peace Service

# មាតិកា


សេចក្តីផ្តើម ..........១
គោលបំណងនៃការសិក្សាស្រាវជ្រាវ ..........២
វិធីសាស្ត្រស្រាវជ្រាវ ..........៣
- និយមន័យនៃពាក្យថា ជនជាតិភាគតិច ..........៤
- បរិបទក្របខ័ណ្ឌគតិយុត្តិ ..........៥
- បរិបទសេដ្ឋកិច្ច-សង្គម ..........៩
- លក្ខខណ្ឌអន្តោប្រវេសន៍ និងលក្ខខណ្ឌរស់នៅពាក់ព័ន្ធនឹងឯកសារគតិយុត្តិ ..........១០

ការសិក្សាស្រាវជ្រាវ ..........១២
- បរិបទទូទៅនៃឯកសារគតិយុត្តិ កូន និងផ្សេងៗ ..........១២
- ច្បាប់ក្នុងស្រុកស្តីពី សញ្ជាតិ និងអន្តោប្រវេសន៍ ..........២៤
- សន្ធិសញ្ញាអន្តរជាតិ ..........២៤

សន្និដ្ឋាន ..........២៥
អនុសាសន៍ ..........២៧
ឯកសារយោង ..........២៩
បញ្ជីក្រាហ្វិក ..........៣១


Thailand
Laos PDR
ODDAR MEAN CHEY
BANTEAY MEANCHEY
SIEM REAP
PREAH VIHEAR
STUNG TRENG
RATANAKIRI
BATTAMBANG
PAILIN
KAMPONG THOM
MONDOL KIRI
KRATIE
PURSAT
VN 1,856F = 11,454P
Cham 1,053F = 4,261P
KK 1,192F = 5,216P
KAMPONG
CHHNANG
VN 2,397=10,087P
CM 7,862F=30,610P
KK 41F = 220P
KAMPONG CHAM
KOH KONG
PHNOM PENH
KAMPONG SPEU
KANDAL
PREY VENG
SVAY RIENG
Vietnam
TAKEO
VN 479F = 867P
Cham 493F = 2,276P
KK 11,226F
38,767P
KAMPOT
PREAH SIHANOUK
KEP

## ១- សេចក្តីផ្តើម

### ១.១- ប្រវត្តិនៃការសិក្សាស្រាវជ្រាវ

ស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានប្រជាជនចំនួន ១៥.១៤ លាននាក់ (របាយការណ៍វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១៣) ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាជាច្រើន ដើម្បីជួយលើកកំពស់ការអភិវឌ្ឍន៍ ជាតិ។ ប្រទេសកម្ពុជាគឺជារដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៥១ ស្តីអំពី ឋានៈជនភៀសខ្លួន និងពិធីសារឆ្នាំ១៩៦៧ ដែលបានផ្តល់សច្ចាប័ន កាលពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៩២ ប៉ុន្តែកម្ពុជាមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាឆ្នាំ ១៩៥៤ ពាក់ព័ន្ធនឹងឋានៈជនភាគតិច និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពី ការកាត់បន្ថយជនជាតិភាគតិច[1]។ ជនជាតិភាគតិច គឺជាបញ្ហាមួយដែលនៅតែបន្តមានក្នុងប្រទេស ហើយក៏ជាផ្នែកមួយនៃពិភពលោកផងដែរ។ ទោះជាយ៉ាងណា ប្រទេសកម្ពុជាបានដើរតួយ៉ាងសំខាន់ក្នុងការទប់ស្កាត់ និងកាត់បន្ថយជនជាតិភាគតិច និងការពារសិទ្ធិរបស់ពួកគេ តាមរយៈយន្តការជាច្រើន។ នៅចុងទសវត្សនេះ ជនជាតិភាគតិចក្នុងប្រទេសនៅតែជាបញ្ហាសំខាន់។ វាជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនដែលចាំបាច់ត្រូវដោះស្រាយនៅថ្ងៃអនាគតខាងមុខ។

ជនជាតិភាគតិចដូចជា ជនជាតិវៀតណាម និងខ្មែរក្រោមដែលកំពុងរស់នៅក្នុងប្រទេស ត្រូវបានផ្តោតជាបញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមជាច្រើនក្នុងសង្គមកម្ពុជា។ ជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជាជួបប្រទះនូវបញ្ហាស្មុគស្មាញធ្ងន់ធ្ងរជាច្រើន។ ជនជាតិភាគតិចក្នុងប្រទេសកម្ពុជាបានក្លាយជាបញ្ហាសំខាន់មួយនៅទសវត្សថ្មីនេះ។ វាបានក្លាយជាចំណុចនយោបាយសម្រាប់គណៈបក្សនយោបាយនៅក្នុងប្រទេស។ ជាពិសេស ក្រុមជាតិពន្ធជនជាតិវៀតណាមក្នុងប្រទេសកម្ពុជាគឺជាក្រុមនៃជនជាតិភាគតិចមួយដែលជួបប្រទះហានិភ័យ ស្របពេលដែលខ្មែរក្រោមក៏កំពុងស្ថិតក្នុងស្ថានភាពដូចគ្នានេះផងដែរ។

បច្ចុប្បន្ននេះ ចំនួនពិតប្រាកដនៃជនជាតិភាគតិចមិនត្រូវបានដឹងនោះឡើយ ប៉ុន្តែគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានប៉ាន់ស្មានថា យ៉ាងហោចណាស់មានចំនួន ១០លាននាក់ជាសាកលដែលកំពុងរស់នៅគ្រប់តំបន់ទាំងអស់ទូទាំងពិភពលោក។ ប្រហែល១/៣នៃជនទាំងនេះគឺជាកុមារ។ យ៉ាងណាមិញ យោងតាមស្ថិតិបានបញ្ជាក់ថា មានជនជាតិភាគតិច ១.៤លាននាក់ កំពុងស្ថិតនៅក្នុងភាពហានិភ័យក្នុងតំបន់អាស៊ី ដែលរួមបញ្ចូលទាំងជនជាតិវៀតណាម (១១,៥០០)[2] ប៉ុន្តែចំនួនពិតប្រាកដនៃជនទាំងនេះក្នុងប្រទេសកម្ពុជាមិនត្រូវបានស្គាល់ ឬលាតត្រដាងនោះទេ។ ជនជាតិភាគតិចទាំងនេះ មិនបានទទួលនូវផលប្រយោជន៍សង្គម និងមិនអាចទទួលបាននូវសិទ្ធិសេដ្ឋកិច្ច និងទទួលបានសិទ្ធិនៃសញ្ជាតិនោះទេ។ ដូចនេះ តាមរយៈការសិក្សាស្រាវជ្រាវនេះ គឺធ្វើការអង្កេតនៅស្ថានភាពទាំងនេះនៅក្នុងប្រទេស គុណវិបត្តិចំពោះជនជាតិភាគតិច និងការអន្តរាគមន៍ដែលត្រូវបានដាក់ចេញដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជាក្នុងការដោះស្រាយបញ្ហានេះ។ នេះជាហេតុផលដែលការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើង។

## ២- គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវធ្វើឡើងសម្រាប់គោលបំណងដូចខាងក្រោម៖ ១) ស្រាវជ្រាវលើស្ថានភាពពាក់ព័ន្ធនឹងឯកសារគតិយុត្តិក្នុងចំណោមក្រុមជាតិពន្ធវៀតណាម និងជនភៀសខ្លួនខ្មែរក្រោម និង២)ការជួបលទ្ធផល

[1] ការិយាល័យគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក បញ្ជីរដ្ឋភាគីនៃសន្ធិសញ្ញាក្នុងតំបន់អាស៊ី/ប៉ាស៊ីហ្វិក ចុះថ្ងៃទី កញ្ញា ឆ្នាំ ២០១៤ ទំព័រទី ៧

[2] Ibid ទំព័រទី ២

ដែលបានរំពឹងទុកតាមរយៈការប្រមូលឋានៈគតិយុត្តិ និងការកាន់កាប់ឯកសារសំគាល់ខ្លួននៃសមាជិកក្រុមជនជាតិភាគតិចវៀតណាម និងខ្មែរក្រោមក្នុងសហគមន៍ផ្សេងៗក្នុងខេត្តចំនួន៣។

## ៣- វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្តោតលើឯកសារគតិយុត្តិក្នុងចំណោមក្រុមជាតិពន្ធុវៀតណាម និងជនភៀសខ្លួនខ្មែរក្រោមក្នុងប្រទេសកម្ពុជា។ ដើម្បីកំណត់ពីវិសាលភាពរបស់វា ការសិក្សាត្រូវបានផ្តោតលើក្រុមជាតិពន្ធុទាំងនេះដែលកំពុងរស់នៅក្នុងប្រទេស។ ការសិក្សាស្រាវជ្រាវមិនត្រឹមតែកំណត់លើឋានៈគតិយុត្តិនោះទេ ប៉ុន្តែក៏មានរួមបញ្ចូលទាំងសិទ្ធិកាន់កាប់របស់ពួកគេ។

## ៤- វិធីសាស្រ្ត

ដើម្បីអនុវត្តវិធីសាស្ត្រក្នុងការស្រាវជ្រាវ គឺបានប្រើកម្រងសំនួរពីឆ្នាំ ២០១៤ និងការសិក្សាស្រាវជ្រាវ នៅកន្លែងនាពេលបច្ចុប្បន្ន យើងនឹងប្រមូលទិន្នន័យជាឯកត្តបុគ្គលតាមរយៈការសម្ភាសន៍ស៊ីជម្រៅជាមួយ សហគមន៍ក្រុមជាតិពន្ធុវៀតណាម ជនភៀសខ្លួនខ្មែរក្រោម និងអាជ្ញាធរពាក់ព័ន្ធ រយៈពេល២ទៅ៤ថ្ងៃក្នុងខេត្តនីមួយៗ។ ក្រុមគម្រោងនឹងសហការជាមួយអ្នកប្រឹក្សាយោបល់ដើម្បីបង្កើតទម្រង់សំនួរ ភូមិសាស្ត្រដែនទី និងការសាកល្បងកម្រងសំនួរ។ ការសម្ភាសន៍នឹងធ្វើឡើងចំនួន៤ (៣កន្លែងមកពីភ្នំពេញ និង១កន្លែងនៅខេត្ត)។ យើងប៉ាន់ស្មានថានឹងមានការឆ្លើយតបប្រហែល១២០ក្នុងខេត្តនីមួយៗ។ រាល់ព័ត៌មានទាំងអស់ត្រូវបានបញ្ចូលទៅក្នុងកម្មវិធី SPSS។ SPSS ជាកម្មវិធីមួយដែលត្រូវបានប្រើដើម្បីវិភាគទិន្នន័យដោយមានការគាំទ្រយ៉ាងធំធេងពីកម្មវិធី Microsoft Excel។ នេះគឺជាការសិក្សាស្រាវជ្រាវដោយប្រើប្រាស់កម្រងសំនួរ។ អ្នកសម្ភាសន៍បានធ្វើការសម្ភាសន៍ដោយជួបផ្ទាល់នាកន្លែងសមរម្យដែលភាគច្រើនគឺគេហដ្ឋានរបស់អ្នកត្រូវបានសម្ភាសន៍។ មានមនុស្សចំនួន ៤១៤ត្រូវបានសម្ភាសន៍ក្នុងខេត្តចំនួន៣ ដែលមានក្រុមជនជាតិភាគតិចចំនួន ៤០២ និងអាជ្ញាធរក្នុងស្រុកចំនួន ១២។ បន្ថែមពីនេះ ការសិក្សាក៏បានដកស្រង់ចេញពីផ្នែកសំខាន់ខ្លះៗនៃច្បាប់ស្តីពី សញ្ជាតិខ្មែរ និងច្បាប់អន្តរជាតិ ដែលត្រូវយកមកធ្វើជាឯកសារយោងក្នុងការសិក្សានេះ។

## ៥- ទីកន្លែងសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងក្នុងខេត្ត៣ គឺខេត្តតាកែវ (១២៣) ខេត្តកំពង់ឆ្នាំង (១២៣) និងខេត្តពោធិ៍សាត់ (១៣៧)។ គួរកត់សម្គាល់ថា មានកម្រងសំនួរចំនួន១៩ មិនត្រូវបានបញ្ជាក់ពីឈ្មោះនៃខេត្តណាមួយ ដូចនេះវាមិនត្រូវបានរាប់បញ្ចូលឡើយ។

## ៦- សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

កាសិក្សាស្រាវជ្រាវនេះនឹងក្លាយជាជំនួយដ៏ពិសេស និងសំខាន់ ដូចខាងក្រោម៖

ទី១ ការសិក្សានឹងបង្ហាញពីឯកសារអ្វីខ្លះដែលក្រុមជាតិពន្ធុវៀតណាម និងជនភៀសខ្លួនខ្មែរក្រោម មានសម្រាប់ការរស់នៅក្នុងប្រទេសកម្ពុជា ព្រមទាំងបង្ហាញលិខិតកាន់កាប់របស់ពួកគេដើម្បីដោះស្រាយសិទ្ធិកាន់កាប់របស់ពួកគេ។ ដូចនេះ វាមានសារៈសំខាន់ណាស់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធផ្សេងទៀត ដែលប្រតិបត្តិការក្នុងប្រទេស ជាពិសេស អង្គការ MIRO ដែលខិតខំប្រឹងប្រែងលើកពីកម្រិតនៃភាពដឹងរបស់ខ្លួនពាក់ព័ន្ធនឹងក្រុមជាតិពន្ធុទាំងនេះក្នុងសង្គមកម្ពុជា និងជាកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយ និងទប់ស្កាត់ជនជាតិភាគតិច។

ទី២ ការសិក្សាស្រាវជ្រាវនឹងមានអត្ថប្រយោជន៍ផ្ទាល់ចំពោះអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ជាពិសេស អង្គការដែលធ្វើការសំដៅទៅលើការការពារជនជាតិភាគតិច ដែលជាទូទៅជនជាតិភាគតិចមកពីខ្មែរក្រោម (សញ្ជាតិខ្មែរ) និងក្រុមជនជាតិភាគតិចវៀតណាម។ ការសិក្សានេះពណ៌នាអំពីរបៀបនៃការរស់នៅរបស់ពួកគេក្នុងប្រទេស កម្ពុជា។ ការសិក្សារកឃើញនេះជួយឲ្យពួកគេយល់ពីសិទ្ធិផ្លូវច្បាប់នៅក្នុងប្រទេស និងផ្តល់ឲ្យគេនូវព័ត៌មានពីវិធីដែលអាចជួយពួកគេរស់នៅស្របច្បាប់ និងទទួលបានសញ្ជាតិដោយផ្អែកលើច្បាប់ជាតិ។

ចុងបញ្ចប់ ការសិក្សានេះនឹងដើរតួនាទីជាឧបករណ៍មួយសម្រាប់បំពេញបន្ថែមចន្លោះរវាងរដ្ឋាភិបាល និងការខិតខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីកាត់បន្ថយ និងទប់ស្កាត់ជនជាតិភាគតិច និងការពារសិទ្ធិរបស់ពួកគេក្នុងប្រទេសកម្ពុជា ដោយបង្កើតនូវផែនការជាក់ច្បាស់ ដែលនឹងនាំឲ្យជនទាំងនោះស្ថិតក្នុងស្ថានភាពល្អប្រសើរ និងគោរពតាមច្បាប់ជាតិ និងអន្តរជាតិ។

## ៧- <u>វិធីសាស្ត្រស្រាវជ្រាវ</u>

អន្តោប្រវេសន៍ភាពបានក្លាយជាក្តីបារម្ភទូទៅមួយសម្រាប់ប្រទេសទាំងអស់លើពិភពលោក។ ការផ្លាស់ទីកន្លែងរបស់មនុស្សក្នុងប្រទេសមួយ ឬឆ្លងកាត់ព្រំដែនរបស់ខ្លួន គឺជាបញ្ហាគោលការណ៍សំខាន់មួយ ជាពិសេស ក្នុងក្របខ័ណ្ឌសាកលភាវូបនីយកម្ម និងសមាហរណកម្ម។ លំហូរមូលធន ទំនិញ និងព័ត៌មានតាមព្រំដែនប្រទេសគឺបច្ចុប្បន្នមិនអាចគេចផុតនោះទេ។ ស្របពេលជាមួយនឹងលំហូរនេះ បំលាស់ទីរបស់មនុស្ស និងកម្មករពីប្រទេសកំណើតរបស់ពួកគេដើម្បីរកឱកាសសេដ្ឋកិច្ចល្អប្រសើរគ្រប់ទីកន្លែង គឺកំពុងកើនឡើង។ នេះជាបញ្ហាសំខាន់សម្រាប់ប្រទេសទាំងអស់ ក្នុងការគ្រប់គ្រងអន្តោប្រវេសន៍ភាពឲ្យមានប្រសិទ្ធិភាព និងដើម្បីការពារសិទ្ធិស្របច្បាប់នៃអន្តោប្រវេសន៍ទាំងនោះ។ សព្វថ្ងៃនេះ ការបំលាស់ទីរបស់ជនទាំងនោះ បានក្លាយជាជនជាតិភាគតិចក្នុងពិភពលោក។ បន្ថែមលើសពីនេះ បច្ចុប្បន្នប្រទេសកម្ពុជាបាននឹងកំពុងប្រឈមនឹងបញ្ហានេះ ដែលរដ្ឋា ភិបាលកម្ពុជាគួរតែដោះស្រាយ។

### ៧.១- <u>និយមន័យនៃពាក្យ ជនជាតិភាគតិច</u>

ក្នុងឆ្នាំ១៩៥១ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រជុំសន្និបាតពេញអង្គ ដើម្បីព្រាងនូវសន្ធិសញ្ញាអន្តរជាតិមួយស្តីពី ជនភៀសខ្លួន និងជនជាតិភាគតិច និងអនុសញ្ញាពាក់ព័ន្ធនឹងឋានៈជនភៀសខ្លួន ត្រូវបានឯកភាពក្នុងឆ្នាំនោះ ហើយការចរចាជាអន្តរជាតិស្តីពី ភាពចាំបាច់នៃការការពារជនជាតិភាគតិចក៏បានបន្តចាប់ផ្តើម។ នៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ១៩៥៨ អនុសញ្ញាពាក់ព័ន្ធនឹងឋានៈជនជាតិភាគតិចត្រូវបានបង្កើតឡើង និងបានចូលជាធរមាននៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ១៩៦០។ អនុសញ្ញានេះបានបង្កើតក្របខ័ណ្ឌមួយសម្រាប់ការការពារជាអន្តរជាតិលើជនជាតិភាគតិច ហើយក៏ជាឯកសារដ៏ទូលំទូលាយនៃសិទ្ធិជនជាតិភាគតិច ដែលបានបង្កើតក្នុងកម្រិតអន្តរជាតិ។ អនុសញ្ញាឆ្នាំ ១៩៥៤ ជាការបង្កើតដ៏សំខាន់នៃច្បាប់អន្តរជាតិ បានឲ្យនិយមន័យនៃពាក្យថាជនជាតិភាគតិច *"គឺជនទាំងឡាយណាដែលមិនត្រូវបានចាត់ទុកថាជាជនជាតិមួយនៃរដ្ឋណាមួយស្ថិតក្រោមប្រតិបត្តិការនៃច្បាប់នេះ"* ។ (កំណត់សម្គាល់ផ្តើម ចែងដោយការិយាល័យគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាតិទទួលបន្ទុកជនភៀសខ្លួន ទីក្រុងហ្សឺណែវ ខែឧសភា ឆ្នាំ២០១៤ កែសម្រួលឡើងវិញ កាលពី ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៦ពី http://www.unhcr.org/protection/statelessness/3bbb25729/convention-relating-status-stateless-persons.html)។ អ្នកដែលបំពេញតាមលក្ខខណ្ឌនៃភាពជាជនជាតិភាគតិចនោះ អនុសញ្ញានឹងផ្តល់ជូននូវស្តង់ដារអប្បបរមា។ ស្តង់ដារបានកំណត់ថា ជនជាតិភាគតិចនឹងទទួលបានសិទ្ធិ ដូចគ្នា

នឹងនៃសញ្ជាតិ ដោយទទួលបានសិទ្ធិសាសនា និងការអប់រំកូនៗរបស់ពួកគេ។ តាមការដកស្រង់ពី អត្ថបទនៃអនុសញ្ញាឆ្នាំ ១៩៥៤ ពាក់ព័ន្ធនឹងឋានៈរបស់ជនជាតិភាគតិចចែងថាៈ

***មាត្រា១* និយមន័យនៃពាក្យ "ជនជាតិភាគតិច"**

១- ស្របតាមគោលបំណងនៃអនុសញ្ញានេះ ពាក្យថា "ជនជាតិភាគតិច" មានន័យថា ជនណាម្នាក់ដែលមិនត្រូវបានចាត់ទុកថាជាជនជាតិមួយនៃរដ្ឋណាមួយស្ថិតក្រោមប្រតិបត្តិការនៃច្បាប់នេះ។

២- អនុសញ្ញានេះមិនត្រូវអនុវត្តចំពោះៈ

(i) ជនដែលបច្ចុប្បន្នទទួលបានការការពារ ឬជំនួយពីអង្គភាព ឬភ្នាក់ងារនៃអង្គការសហប្រជាជាតិក្រៅពីគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន

(ii) ជនដែលត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស ដែលពួកគេបានស្នាក់នៅហើយទទួលបានសិទ្ធិ និងកាតព្វកិច្ចដែលភ្ជាប់ទៅនឹងការកាន់កាប់សញ្ជាតិនៃប្រទេសនោះ

(iii) ជនដែលត្រូវបានចាត់ទុកថាមានហេតុផលធ្ងន់ធ្ងរ ដូចជាៈ

(ក) បានប្រព្រឹត្តបទល្មើសប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម ឬបទល្មើសប្រឆាំងមនុស្សជាតិ ដូចដែលបានកំណត់ក្នុងលិខិតតុបករណ៍អន្តរជាតិ

(ខ) បានប្រព្រឹត្តបទល្មើសមិនមែននយោបាយធ្ងន់ធ្ងរក្រៅប្រទេសដែលពួកគេស្នាក់នៅមុនពេលទទួលបានការអនុញ្ញាតឲ្យស្នាក់នៅប្រទេសនោះ

(គ) បានប្រព្រឹត្តសកម្មភាពឃោរឃៅផ្ទុយនឹងគោលបំណង និងគោលការណ៍អង្គការសហប្រជាជាតិ។

ដោយសារតែការការពារជនជាតិភាគតិចមិនមែនប្រើសម្រាប់ទទួលបានសញ្ជាតិនោះ អនុសញ្ញាបានកំណត់ថា រដ្ឋទាំងអស់ត្រូវសម្រួលសមានកម្ម និងធ្វើជាតូបនីយកម្មដល់ជនជាតិភាគតិចទាំងនោះ។ ហេតុដូចនេះ អនុសញ្ញាឆ្នាំ១៩៥១ ស្តីអំពីឋានៈជនភៀសខ្លួន អនុសញ្ញាឆ្នាំ១៩៥៤ ដាក់ច្បាស់មិនរាប់បញ្ចូលជនណាដែលត្រូវបានរកឃើញថា បានប្រព្រឹត្តបទល្មើសប្រឆាំងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម បទល្មើសប្រឆាំងមនុស្សជាតិ ឬបទល្មើសមិនមែននយោបាយធ្ងន់ធ្ងរក្រៅប្រទេស។ ការិយាល័យនៃគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ត្រូវបានទទួលអាណត្តិក្នុងការជួយជនជាតិភាគតិចចាប់តាំងពី អង្គការនេះត្រូវបានបង្កើតឡើង នៅថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៥១មក។ ចាប់តាំងពីអនុសញ្ញាឆ្នាំ១៩៥៤ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពី ការកាត់បន្ថយជនជាតិភាគតិចបានចូលជាធរមានមក មានសេចក្តីសម្រេចរបស់មហាសន្និបាត និងសេចក្តីសន្និដ្ឋានជាច្រើន ឯកភាពដោយគណៈកម្មាធិការប្រតិបត្តិនៃកម្មវិធីរបស់គណៈកម្មាធិការជាន់ខ្ពស់ បានផ្តល់ដល់គណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួននូវតួនាទីដឹកនាំ ជួយសម្រួលជនជាតិមិនមែនភាគតិចជាប្រជាជនជាក់លាក់មួយ (កំណត់សម្គាល់ផ្តើមដោយការិយាល័យនៃ គណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ទីក្រុងហ្សឺណែវ ឧសភា ឆ្នាំ២០១៤)។

## ៧.២- <u>បរិបទក្របខ័ណ្ឌគតិយុត្តិ</u>

អនុសញ្ញាឆ្នាំ ១៩៥៤ គឺជាការបង្កើតដ៏សំខាន់នៃច្បាប់អន្តរជាតិ បានឲ្យនិយមន័យថា *"ជនជាតិភាគតិចគឺជនទាំងឡាយណាដែលមិនត្រូវបានចាត់ទុកថាជាជនជាតិមួយនៃរដ្ឋណាមួយ ស្ថិតក្រោមប្រតិបត្តិការនៃច្បាប់នេះ"*។ អនុសញ្ញាឆ្នាំ ១៩៥៤ ស្តីពី ឋានៈនៃជនជាតិភាគតិចមានសារៈសំខាន់បំផុត ខណៈដែលប្រជាជនរាប់លាននាក់ពាសពេញពិភពលោកបន្តជួបប្រទះបញ្ហាជាច្រើន ដោយសារតែពួកគេជាជនជាតិភាគតិច។ តាមការ

អំពាវនាវរបស់គណៈកម្មាធិការជាន់ខ្ពស់ ដើម្បីលុបបំបាត់ជនជាតិភាគតិចត្រឹមឆ្នាំ ២០២៤ គណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនកំពុងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបញ្ចុះបញ្ចូលរដ្ឋទាំងអស់ឲ្យឯកភាពលើសន្ធិសញ្ញាទាំងពីរ។ អនុសញ្ញាឆ្នាំ១៩៥៤ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពី ជនជាតិភាគតិចមានអង្គភាពច្បាស់លាស់សម្រាប់ការសិទ្ធិមនុស្សរបស់ជនភាគតិច និងសម្រាប់ទប់ស្កាត់ និងកាត់បន្ថយជនទាំងនោះ (កំណត់សម្គាល់ផ្តើម ដោយការិយាល័យនៃគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ទីក្រុងហ្សឺណែវ ឧសភា ឆ្នាំ២០១៤ ) កែសម្រួលឡើងវិញ កាលពីថ្ងៃទី 0៤ ខែសីហា ឆ្នាំ២០១៦ពី http://www.unhcr.org/protection/statelessness/3bbb25729/convention-relating-status-stateless-persons.html)។ យោងតាមអត្ថបទនៃអនុសញ្ញាឆ្នាំ១៩៦១ស្តីពី ការកាត់បន្ថយជនជាតិភាគតិច ត្រូវបានឯកភាពកាលពីថ្ងៃទី ៣0 ខែសីហា ឆ្នាំ១៩៦១ និងចូលជាធរមាននៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ១៩៧៥។ វាបំពេញបន្ថែមអនុសញ្ញាឆ្នាំ១៩៥៤ ពាក់ព័ន្ធនឹងឋានៈនៃជនជាតិភាគតិច ហើយក៏ជាលទ្ធផលនៃការចរចាជាអន្តរជាតិជាច្រើនទសវត្ស ស្តីអំពី វិធីជៀសវៀងការកើតនៃជនជាតិភាគតិច។ សន្ធិសញ្ញាទាំងពីរនេះបង្កើតនូវមូលដ្ឋានគ្រឹះនៃ**ក្របខ័ណ្ឌគតិយុត្តិអន្តរជាតិ**ដើម្បីដោះស្រាយបញ្ហាជនជាតិភាគតិច ជាបាតុភូតមួយដែលបន្តជះឥទ្ធិពលមិនល្អដល់ការរស់នៅរបស់ប្រជាជនរាប់លាននាក់ជុំវិញពិភពលោក។ អនុសញ្ញាឆ្នាំ១៩៦១ គឺលិខិត តុបករណ៍អន្តរជាតិឈានមុខគេដែលកំណត់វិធានសម្រាប់ការប្រគល់ និងការដកហូតសញ្ជាតិ ដើម្បីទប់ស្កាត់ករណីនៃកើតឡើងនៃជនជាតិភាគតិច។

តាមរយៈការបង្កើតវិធាននានាដើម្បីលុបបំបាត់ការកើតឡើងនៃជនជាតិភាគតិច អនុសញ្ញាបានថែងជាវិជ្ជមានទៅនឹងមាត្រា១៥នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ដែលបានទទួលស្គាល់ថា "ជនគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិ"។ មូលដ្ឋានៃអនុសញ្ញាឆ្នាំ១៩៦១ គឺជាសញ្ញាណខណៈពេលដែលរដ្ឋជាច្រើនរក្សានូវសិទ្ធិដើម្បីពិនិត្យពិច័យអត្ថន័យនៃច្បាប់សញ្ជាតិរបស់ពួកគេ ដែលត្រូវឲ្យស្របគ្នាជាមួយបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងសញ្ជាតិ ដោយរួមបញ្ចូលទាំងគោលការណ៍ដែលជនជាតិភាគតិចគួរជៀសវាង។ តាមរយៈការអនុម័តអនុសញ្ញាឆ្នាំ១៩៦១ បានការពារទប់ស្កាត់នូវជនជាតិភាគតិច រដ្ឋនានាបានចូលរួមកាត់បន្ថយបញ្ហានេះ។ បន្ថែមលើសពីនេះ អនុសញ្ញាឆ្នាំ១៩៦១បានបង្កើតវិធានការការពារប្រឆាំងនឹងជនជាតិភាគតិចតាមបរិបទផ្សេងៗគ្នាជាច្រើន។ ចំណុចស្នូលនៃអនុសញ្ញានេះគឺទប់ស្កាត់ការកើតជនជាតិភាគតិចតាមរូបភាពផ្តល់កំណើត ដោយតម្រូវឲ្យរដ្ឋផ្តល់សញ្ជាតិឲ្យកូនដែលបានកើតលើទឹកដីរបស់ពួកគេ ឬកើតនៅបរទេស ដែលក្រៅពីជនភាគតិច។ ដើម្បីទប់ស្កាត់ជនភាគតិចតាមករណីទាំងនេះ រដ្ឋត្រូវផ្តល់នូវសញ្ជាតិទៅកូនដោយស្វ័យប្រវត្តិ ឬតាមការស្នើសុំ។

អនុសញ្ញាបានថែងបន្ថែមនូវការទប់ស្កាត់ជនជាតិភាគតិចពេញមួយជីវិត ដោយហាមឃាត់ការដកហូតសញ្ជាតិពីរដ្ឋដែលផ្តល់សញ្ជាតិ ទាំងតាមរយៈការបាត់ ការលះបង់ចោល ឬការបន្ថយសញ្ជាតិទៀតផង។ ចុងបញ្ចប់ អនុសញ្ញាបានណែនាំឲ្យរដ្ឋនានាជៀសវាងភាពជាជនជាតិភាគតិចក្រោមបរិបទនៃការផ្ទេរទឹកដី។ ជាសេនារិយោសម្រាប់បញ្ញត្តិទាំងនេះ អនុសញ្ញាឆ្នាំ១៩៦១កំណត់ថា ការការពារត្រូវបានអនុវត្តត្រឹមតែទីកន្លែងដែលជនជាតិភាគតិចកើតឡើង និងសម្រាប់បុគ្គលឯកជនដែលភ្ជាប់ជាមួយនឹងប្រទេស។ អនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយជនជាតិភាគតិច បច្ចុប្បន្នមានសារៈសំខាន់ណាស់ ខណៈដែលស្ថានភាពជនទាំងនេះ និងប្រទេសនានាបានកើតឡើង។ វាមានសារៈសំខាន់ដែលតម្រូវឲ្យបទបញ្ញត្តិនៃអនុសញ្ញានេះ ត្រូវបានសបញ្ជ្រាបទូលំទូលាយ ហើយភាគីពាក់ព័ន្ធទាំងអស់ត្រូវប្រឹងប្រែងដើម្បីបង្កើនចំនួននៃការភ្ជាប់ខ្លួនទៅនឹងអនុសញ្ញានេះ ដើម្បីដោះស្រាយបញ្ហានេះនៅជុំវិញពិភពលោក (អនុសញ្ញាស្តីពី ការកាត់បន្ថយជនជាតិភាគតិចឆ្នាំ១៩៦១ កែសម្រួលឡើងវិញ កាលពីថ្ងៃទី 0៤ ខែសីហា ឆ្នាំ២០១៦ពី http://www.unhcr.org/protection/statelessness/3bbb25729/convention-relating-status-stateless-persons.html)។)

ចំពោះគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (២០១៤) តើសកម្មភាពនេះត្រូវបានអនុវត្តយ៉ាងដូចម្តេច? ដំណោះស្រាយដ៏ល្អបំផុតដើម្បីដោះស្រាយស្ថានភាពនៃជនជាតិភាគតិចគឺតាមរយៈការផ្លាស់ប្តូរគោលការណ៍រដ្ឋាភិបាល ឬនីតិបញ្ញត្តិ រួមមានវិធានការតែមួយក្នុងការទទួលស្គាល់សញ្ជាតិចំពោះប្រជាជនទាំងនោះ ដែលមិនបានរាប់បញ្ចូលនៅពេលរដ្ឋឯករាជ្យ។ វិធានស្តីពីការប្រគល់សញ្ជាតិអាចត្រូវបានផ្លាស់ប្តូរ ធ្វើឲ្យជនទាំងនោះស្នាក់ដែលនៅក្នុងទឹកដី អាចត្រូវបានគេពិចារណាលើសញ្ជាតិ ដែលបានផ្តល់តាមការយៈកំណើតលើទឹកដី ឬបានរស់នៅទីនោះមុនពេលវេលាជាក់លាក់ ឬមានឪពុក-ម្តាយ ឬជីដូន-ជីតាដែលបំពេញតាមលក្ខខណ្ឌនេះ។ លក្ខខណ្ឌ និងនីតិវិធីសម្រាប់សញ្ជាតូបនីយកម្មអាចត្រូវបានធ្វើឲ្យងាយស្រួលដើម្បីឲ្យជនជាតិភាគតិចទាំងនោះទទួលបានសញ្ជាតិ ឧទាហរណ៍ តាមរយៈការកាត់បន្ថយចំនួនឆ្នាំរស់នៅដែលតម្រូវ ឬតាមរយៈបន្ថយ ឬលុបបំបាត់ថ្លៃស្នើសុំសញ្ជាតិ។ គណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន អាចជួយវិធានការចម្បងដូចខាងក្រោម៖ ១) ឧបត្ថម្ភ និងផ្តល់ដំបូលន្មានបច្ចេកទេសសម្រាប់កំណែទម្រង់ច្បាប់សញ្ជាតិ គោលការណ៍ និងនីតិវិធីដើម្បីធានាឲ្យបាននូវសមភាពរវាងស្ត្រី និងបុរសលើបញ្ហាអន្តរជាតិ។ នៅពេលដែលអាចអនុវត្តបាន នឹងប្រើប្រាស់កាលានុវត្តភាពនៃដំណើរការកំណែទម្រង់ធម្មនុញ្ញដើម្បីទទួលបាននូវគោលបំណងទាំងនេះ។ ២) សហការជាមួយអង្គការសហប្រជាជាតិ ស្ត្រី មូលនិធិអន្តរជាតិសង្គ្រោះកុមាររបស់អង្គការសហប្រជាជាតិ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងសមាជិកសង្គមស៊ីវិលនៃយុទ្ធនាការសាកលសម្រាប់សមភាពនៃសិទ្ធិសញ្ជាតិ។ ៣) គាំទ្រការផ្តួចផ្តើមដោយសហគមន៍ច្បាប់ដើម្បីលើកកំពស់សមភាពស្ត្រី និងបុរសលើឆាកអន្តរជាតិ រួមមានតាមរយៈយុទ្ធសាស្រ្តក្តីក្នុងគោលបំណងទទួលបាននូវកំណែទម្រង់នីតិបញ្ញត្តិ ឬបញ្ចប់ការរើសអើងនៃទម្រង់ស្នើសុំសញ្ជាតិ។ បង្កើតសមត្ថភាពវិជ្ជាជីវៈច្បាប់ និងផ្នែកយុត្តិធម៌ស្តីពីជនជាតិភាគតិច និងបញ្ហាសញ្ជាតិ (គណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ២០១៤)។ យ៉ាងណាមិញ ច្បាប់របស់កម្ពុជាស្តីពី សញ្ជាតិ និងបទបញ្ញត្តិពាក់ព័ន្ធត្រូវបានអនុវត្តជាលាយលក្ខណ៍អក្សររួចមកហើយ។ ជាការសម្រួលដល់ការយល់ដឹងនៃឋានានុក្រមនៃច្បាប់កម្ពុជា និងបទបញ្ញត្តិដែលអនុវត្តចំពោះក្រុមទាំងនោះ មានបទបញ្ញតិជាច្រើនបច្ចុប្បន្នត្រូវបានអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីមានជម្លោះកើតឡើងរវាងតុបករណ៍ច្បាប់ លិខិតតុបករណ៍ច្បាប់ដែលខ្ពស់ជាងគេមានបុព្វសិទ្ធិ គឺនីតិរដ្ឋធម្មនុញ្ញ។

យោងតាមលោក Lyma Nguyen និងលោក Christoph Sperfeldt (២០១២) បានបង្ហាញថា រដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ស្តីពី សញ្ជាតិ និងបទបញ្ញត្តិពាក់ព័ន្ធដ៏ទៃទៀតត្រូវបានអនុវត្ត។ ទី១ ទោះបីជាច្បាប់ស្តីពីសញ្ជាតិបច្ចុប្បន្នរបស់កម្ពុជាឆ្នាំ១៩៩៦ បានគ្របដណ្តប់ដំណើរការដើម្បីទទួលបានសញ្ជាតិខ្មែរក៏ដោយ ក៏ច្បាប់សញ្ជាតិដែលស្ថិតក្រោមរដ្ឋបាលដំបូងនោះនៅតែពាក់ព័ន្ធនឹងការកំណត់សញ្ជាតិសព្វថ្ងៃ។ តាមការអនុវត្តច្បាប់ជាធរមានចំពោះជនទាំងនោះ ការស្រាវជ្រាវដូចខាងក្រោមត្រូវបានរកឃើញ៖ សមាជិកក្រុមនៃជនទាំងនោះកើតនៅពេលច្បាប់ស្តីពី សញ្ជាតិឆ្នាំ១៩៥៤ ចូលជាធរមាន មានមូលដ្ឋានរឹងមាំទទួលបានការទទួលស្គាល់នូវសញ្ជាតិខ្មែរពីមុនដែលពួកគេទទួលបានដោយស្វ័យប្រវត្តិផ្អែកលើមូលដ្ឋាននៃបញ្ញត្តិ *ទទួលបានសញ្ជាតិ* នៃច្បាប់នេះ។ គ្មានការប៉ាន់ប្រមាណណាមួយ អាចត្រូវបានបង្កើតឡើងលើឋានៈនៃសមាជិកក្រុមជនជាតិភាគតិចក្រោមច្បាប់ជាធរមាន ស្តីពី សញ្ជាតិរបស់វៀតណាមឡើយ ខណៈដែលនីតិបញ្ញត្តិនៃសញ្ជាតិរបស់វៀតណាមមុនឆ្នាំ១៩៨៨ អាចត្រូវបានរកឃើញ ឬស្ថិតនៅទីណានោះឡើយ។ ទី២ អាជ្ញាធរកម្ពុជាមិនបានចាត់ទុកសមាជិកនៃក្រុមទាំងនោះថាជាសញ្ជាតិខ្មែរស្ថិតក្រោមប្រតិបត្តិការនៃច្បាប់កម្ពុជានោះឡើយ ប៉ុន្តែបានចាត់ទុកពួកគេជា "ជនអន្តោប្រវេសន៍" ឬ "ជនបរទេស"។ បន្ថែមពីនេះ ក្រុមនេះមិនអាចធ្វើការចុះបញ្ជីស៊ីវិលក្នុងប្រទេសកម្ពុជា រួមមាន

ការចុះសំបុត្រកំណើតជាដើម។ ចាប់ពីការប្រព្រឹត្តរបស់អាជ្ញាធរវៀតណាមលើក្រុមជនជាតិភាគតិចក្នុងការនិរទេសខ្លួនរបស់ពួកគេក្នុងប្រទេសវៀតណាម និងអ្នកដែលនិរទេសអចិន្ត្រៃទៅកាន់ប្រទេសវៀតណាមនៅពេលបច្ចុប្បន្នបានបង្ហាញថា អាជ្ញាធរវៀតណាមបច្ចុប្បន្នមិនបានពិនិត្យលើក្រុមទាំងនេះថាជាជនជាតិវៀតណាមនោះឡើយ ប៉ុន្តែប្រទេសវៀតណាមបើកចំហរផ្លូវសម្រាប់សញ្ជាតូបនីយកម្ម។ ផ្អែកលើការរកឃើញនេះ របាយការណ៍បានបូកសរុបថា ក្រុមទាំងនេះបានបង្ហាញខ្លួនជាជនជាតិភាគតិច ដែលការសិក្សារកឃើញនេះអាចត្រូវបានលាតត្រដាងតាមរយៈការស្រាវជ្រាវបន្ថែម។ បើពិនិត្យទៅថ្ងៃអនាគតវិញ របាយការបានពិភាក្សាពីវិធីសាស្ត្រសម្រាប់កាត់បន្ថយ និងទប់ស្កាត់ជនជាតិភាគតិចក្នុងចំណោមក្រុមនេះ រួមមាន ការទទួលស្គាល់សញ្ជាតិទទួលស្គាល់ក្រោមច្បាប់មុន និងផ្តល់អនុសាសន៍ទៅកាន់ភាគីពាក់ព័ន្ធ។

បន្ថែមលើសពីនេះ ពាក់ព័ន្ធនឹងប្រជាជនខ្មែរក្រោមសព្វថ្ងៃ ពួកគេកំពុងប្រឈមនឹងស្ថានភាពរស់នៅដែលនេះជាបញ្ហាសំខាន់ដែលត្រូវព្រួយបារម្ភសម្រាប់ "បញ្ហាដែលត្រូវបានលាក់បាំង" របស់ក្រុមជនជាតិភាគតិចនេះ។ ការធ្វើឲ្យប្រសើរឡើងជំហានដំបូងនៃស្ថានភាពរបស់ខ្មែរក្រោមក្នុងប្រទេសកម្ពុជាអាចទទួលបានលទ្ធផលប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាពិចារណាការអនុវត្តផ្លូវការលើសញ្ជាតិរបស់ខ្មែរក្រោម ទៅក្នុងច្បាប់សញ្ជាតិស្តីពីសញ្ជាតិ ពិនិត្យឡើងវិញលើការរើសអើងដំណើរការស្នើសុំសញ្ជាតិ និងអនុវត្តតាមធម្មនុញ្ញរបស់ខ្លួន ព្រមទាំងទំនួលខុសត្រូវ។ អាជ្ញាធរវៀតណាមចាំបាច់ត្រូវធ្វើឲ្យប្រសើរឡើងនូវការគោរពសិទ្ធិជាមូលដ្ឋាន និងសេរីភាពសាសនាដល់សហគមន៍ខ្មែរក្រោមដើម្បីរក្សានូវអត្តសញ្ញាណ និងវប្បធម៌ជាក់លាក់របស់ពួកគេ (Laura Marcia Kirchner ២០១៥)។ ចាប់តាំងពីពេលនោះ មាត្រា១៩នៃច្បាប់ស្តីពី សញ្ជាតិឆ្នាំ១៩៩៦ បានចែងថា មានតែអ្នកមានសញ្ជាតិខ្មែរប៉ុណ្ណោះមានសិទ្ធិទទួល និងកាន់កាប់អត្តសញ្ញាណបណ្ណ និងលិខិតឆ្លងដែន។ ការទទួលបានអត្តសញ្ញាណបណ្ណគឺជាគន្លឹះដែលចូលរួមជីវិតស៊ីវិល ដែលបើកចំហរយន្តការក្នុងការចុះឈ្មោះបោះឆ្នោត ទទួលសំបុត្រកំណើត និងសំបុត្រអាពាហ៍ពិពាហ៍ បម្រើការងារ បើកគណៈនីធនាគារ ទទួលលទ្ធកម្មទ្រព្យសម្បត្តិ និងដី បើកអាជីវកម្ម និងទទួលឯកសារធ្វើដំណើរ។ ការទទួលបាននូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ គឺមានសារៈសំខាន់ណាស់ព្រោះថាវាបង្ហាញថាអ្នកគឺមានសញ្ជាតិខ្មែរ។

## ៧.៣- __បរិបទសេដ្ឋកិច្ច-សង្គម__

ផ្អែកតាមនាយកដ្ឋានកុលស៊ុល ក្រសួងការបរទេសវៀតណាម (២០១២) បានចែងថា ក្នុងបរិបទនៃការអភិវឌ្ឍន៍ដ៏ស្មុកស្មាញកើតឡើងពាសពេញពិភពលោកនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមក្នុងប្រទេសវៀតណាមនោះ កាលានុវត្តភាពថ្មីបានលើកទឹកចិត្តឲ្យអ្នកមានសញ្ជាតិវៀតណាមរៀបការនៅឯបរទេស។ ប៉ុន្មានឆ្នាំថ្មីៗនេះ លំហូរអាពាហ៍ពិពាហ៍បានធ្វើពិពិធកម្មយ៉ាងសំខាន់។ តម្រូវការនៃស្តង់ដាររស់នៅ ចំណូល និងលក្ខខណ្ឌសន្តិសុខសង្គម បានបន្តជម្រុញឲ្យជនជាតិវៀតណាមបំលាស់ទី។ ការអភិវឌ្ឍន៍ប្រទេសក្នុងរយៈពេល២៥ឆ្នាំរបស់វដ្តការ Doi Moi គួបផ្សំនឹងគោលនយោបាយបើកចំហររបស់វៀតណាម និងសមាហរណកម្មអន្តរជាតិ បានផ្តល់ឲ្យវៀតណាមបំលាស់ទីទៅបរទេសដើម្បីធ្វើការងារ សិក្សា ទស្សនៈកិច្ច ឬស្នាក់នៅ។ បច្ចុប្បន្ន ប្រជាជនវៀតណាមរាប់លាននាក់កំពុងធ្វើការ សិក្សា និងស្នាក់នៅក្រៅប្រទេស។ ការបំលាស់ទីកំពុងកើនឡើង ខណៈដែលកម្រិតនៃការធ្វើអន្តោប្រវេសន៍ក៏បានកើនឡើងដែរ។ ដូចគ្នានេះដែរ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយអភិវឌ្ឍឯករាជ្យឈានមុខរបស់កម្ពុជា (២០០៩) បានបង្ហាញថា មានការចាប់អារម្មណ៍លើការលើកកំពស់សហប្រតិបត្តិការក្នុងមហាអនុតំបន់ទន្លេមេគង្គ ខណៈពេលដែលហេតុផលនៃការបំលាស់ទីដើម្បីធ្វើការងារ គឺកើនឡើងដូចគ្នាសម្រាប់រាល់ជនភៀសខ្លួន ហើយវិធីសាស្ត្រក្នុងការធ្វើដំណើរមានការប្រែប្រួលយ៉ាងខ្លាំងរវាងក្រុមផ្សេងគ្នាដែលឆ្លោះទៅរកប្រទេសក្នុង និងក្រោមមហាអនុតំបន់ទន្លេមេគង្គ។ ការបញ្ចូលគ្នានៃខេត្តយូណានរបស់ចិន វៀតណាម ថៃ ភូមា

ឡាវ និងប្រទេសកម្ពុជា គឺនៅតែមានភាពខុសប្លែកគ្នាគួរឲ្យកត់សម្គាល់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមក្នុងចំណោមប្រទេសទាំង៦នេះ។ លំហូរនៃការបំលាស់ទីពីប្រទេសវៀតណាមដែលកំពុងស្វែងរកឱកាសការងារល្អក្នុងប្រទេសកម្ពុជា ឡាវ និងប្រទេសថៃកំពុងមានការកើនឡើង។

ដោយសារប្រវត្តិសាស្ត្របច្ចុប្បន្នរបស់ប្រទេសវៀតណាម ភាគច្រើននៃជនជាតិវៀតណាមបានបំលាស់ទីមកកម្ពុជា ខណៈកុមារនៅតែក្លាយជាជនជាតិភាគតិចដ៏ច្រើន និងងាយរងគ្រោះក្នុងអំពើជួញដូរ។ ជាទូទៅ ប្រជាជនវៀតណាមត្រូវបានសង្កេតឃើញថាឧស្សាហ៍ និងស្រស់ស្អាតដោយសង្គមកម្ពុជា ធ្វើឲ្យមានតម្រូវការជនអន្តោប្រវេសន៍វៀតណាម (UNIAP ២០០៨)។ ដូចគ្នាទៅនឹងការដកស្រង់របាយការណ៍ពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (២០១១) បានលើកឡើងថា ទោះបីជាខ្មែរក្រោមមានបំណងរក្សាវប្បធម៌ និងអត្តសញ្ញាណសាសនារបស់ពួកគេយ៉ាងណាក៏ដោយ ក៏របបកុម្មុយនីស្តវៀតណាមាបានដាក់ចេញវិធានការដើម្បីឲ្យដូច និងទៅជាជនជាតិវៀតណាមខ្មែរក្រោម ដោយលុបបំបាត់តម្លៃ និងធម្មនិយមរបស់ពួកគេ។ ស្ថិតក្រោមកណ្តាប់ដៃរបស់រដ្ឋាភិបាលវៀតណាម ខ្មែរក្រោមបានក្លាយទៅកន្លែងធ្វើទុក្ខបុកម្នេញវប្បធម៌ និងសាសនា តាមរយៈការរិតត្បិតលើកន្លែងបង្រៀនភាសាខ្មែរ និងពុទ្ធសាសនាថេរវាទ ដែលជាទម្រង់នៃការអនុវត្តពុទ្ធសាសនាដោយប្រជាជនខ្មែរ។ បន្ថែមលើសពីនេះ ប្រវត្តិសាស្ត្រនៃការលេបត្របាក់ទឹកដីដោយរដ្ឋាភិបាលវៀតណាមមកលើតំបន់ដី សណ្តទន្លេមេគង្គរបស់ខ្មែរក្រោមនេះ បានធ្វើឲ្យខ្មែរក្រោមលិចលង់ និងក្លាយជាផ្នែកមួយនៃសង្គមវៀតណាម។ សហគមន៍ខ្មែរក្រោមណាដែលនិយាយប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញនេះ នឹងត្រូវបានចាប់ខ្លួនពីបទជាប់ពាក់ព័ន្ធនឹងសកម្មភាពដែលកំណត់ដោយគោលនយោបាយសាមគ្គីភាពរបស់ជាតិវៀតណាម។ ជាលទ្ធផលនៃការរិតត្បិតទាំងនេះ និងដើម្បីរត់គេចពីការធ្វើទុក្ខបុកម្នេញដោយផ្ទាល់ ខ្មែរក្រោមជាច្រើននាក់បានចាកចេញពីប្រទេសវៀតណាមដើម្បីស្វែងរកជីវិតល្អប្រសើរនៅប្រទេសជិតខាង ពិសេសក្នុងទឹកដីប្រទេសកម្ពុជា។

លោក Lyma Nguyen និងលោក Christoph Sperfeldt (២០១២) បានបង្ហាញថា ក្នុងកម្មវិធីស្រាវជ្រាវឆ្នាំ២០០៨ អ្នកដែលត្រូវបានសម្ភាសន៍ទាំង៧០នាក់មកពីខេត្តកំពង់ឆ្នាំងបញ្ជាក់ថា ពួកគេខ្វះខាតឯកសារពាក់ព័ន្ធនឹងសញ្ជាតិខ្មែរ។ គួរកត់សម្គាល់ដែរថា ទិន្នន័យទទួលបានពីខេត្តកំពង់ឆ្នាំងខុសគ្នាពីទិន្នន័យទទួលបានពីខេត្តពោធិ៍សាត់ និងខេត្តកណ្តាល ដែលជាកន្លែងដែលក្រុមជាតិពន្ធវៀតណាមភាគច្រើនបែរជាទទួលបានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ គួរឲ្យចាប់អារម្មណ៍លើព័ត៌មានដែលមាននាពេលបច្ចុប្បន្នបង្ហាញថា ភាពខុសប្លែកគ្នានេះគឺគ្មានទំនាក់ទំនងពីក្រុមជាតិពន្ធវៀតណាមដែលកើតក្នុងប្រទេសកម្ពុជា ឬនិយាយភាសាខ្មែរនោះទេ។ ដូចនេះ ផ្អែកលើការពន្យល់ផ្សេងពីនេះអាចពាក់ព័ន្ធនឹងសកម្មភាពរបស់អាជ្ញាធរខេត្ត ក្នុងការចេញឯកសារផ្តល់សញ្ជាតិខ្មែរជូនដល់ក្រុមជនជាតិភាគតិចទាំងនេះ និង/ឬ ស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌរស់នៅក្នុងភូមិបណ្តែតទឹកដែលជាកន្លែងអ្នកត្រូវបានសម្ភាសន៍រស់នៅ។

បន្ថែមពីនេះ ផ្អែកលើរបាយការណ៍លោក Nicolas Lainez (២០១១) បានបង្ហាញថា មិនត្រូវបានរាប់បញ្ចូលពីជនជាតិខ្មែរ និងជនជាតិភាគតិចដែលមិនមែនជនជាតិវៀតណាមនោះទេ ពួកគេគឺរស់នៅក្នុងដែនរដ្ឋបាល និងស្របច្បាប់។ ហេតុដូច្នេះហើយ ជនជាតិវៀតណាមត្រូវប្រឈមមុខនឹងបញ្ហារដ្ឋបាល សេដ្ឋកិច្ច-សង្គម និងនយោបាយជាច្រើនដែលហាមឃាត់ពួកគេមិនឲ្យធ្វើសមាហរណកម្មពេញលេញក្នុងសង្គមកម្ពុជា ដូចជាភាពមិនទៀតនៃរដ្ឋបាល គ្មានសាលារៀន ឬមិនតម្រូវឲ្យមាន អនក្ខរកម្មភាសាខ្មែរ និងវៀតណាម ខ្វះការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងគ្មានសមត្ថភាពទទួលបានការងារដែលតម្រូវសម្រាប់ប្រជាជនកម្ពុជា។ លើសពីនេះ ស្ថានភាពសេដ្ឋកិច្ចរបស់ជនជាតិវៀតណាមដែលស្ថិតក្រោមការស្រាវជ្រាវគឺមានការលំបាក។ បញ្ហានៃការទទួលបានឥនទាន គឺជាបញ្ហាឈានទៅរកភាពក្រីក្រ។

## ៧.៤- លក្ខខណ្ឌអន្តោប្រវេសន៍ និងលក្ខខណ្ឌរស់នៅពាក់ព័ន្ធនឹងឯកសារគតិយុត្តិ

ការបំលាស់ទីរបស់មនុស្សក្នុងប្រទេស ឬទៅកាន់ព្រំដែនរបស់ខ្លួនគឺជាបញ្ហាគោលនយោបាយដ៏សំខាន់ជាពិសេស ក្នុងក្របខណ្ឌនៃសមាហរណកម្ម និងសាកលភាវូបនីយកម្ម។ អន្តោប្រវេសន៍បានក្លាយជាក្តីបារម្ភសម្រាប់ប្រទេសទាំងអស់លើពិភពលោក។ សព្វថ្ងៃ ការបំលាស់ទីរបស់មនុស្ស និងកម្មករពីប្រទេសកំណើតរបស់ពួកគេដើម្បីរកឱកាសសេដ្ឋកិច្ចល្អប្រសើរគឺកំពុងមានការកើនឡើង។ នេះបញ្ហាដ៏សំខាន់ចំពោះគ្រប់រដ្ឋទាំងអស់ក្នុងការគ្រប់គ្រងអន្តោប្រវេសន៍ឲ្យមានប្រសិទ្ធភាព និងដើម្បីការពារសិទ្ធិស្របច្បាប់នៃអ្នកបំលាស់ទីទាំងនោះ។

អន្តោប្រវេសន៍ក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលរួមមានប្រទេសវៀតណាមគឺកំពុងមានការកើនឡើងដោយសារកត្តាជាច្រើនដូចជា ការអភិវឌ្ឍន៍សេដ្ឋកិច្ចមិនគ្រប់ជ្រុងជ្រោយ ការបើកព្រំដែនបន្ថែម មិនតុល្យភាពមប្រជាសាស្ត្រជាដើម។ ក៏មានផងដែរនូវស្ត្រីនីយកម្មនៃអន្តោប្រវេសន៍ជាពិសេសនៅក្នុងស្រុក កសិកម្ម និងការងាររោងចក្រ ហើយមានផងដែរក្នុងលក្ខខណ្ឌអាពាហ៍ពិពាហ៍ (An Revenga ២០០៦)។ ផ្អែកតាមលោក (Lyma Nguyen និងលោក Christoph Sperfeldt (២០១២) បានបង្ហាញថា បើគ្មានសញ្ជាតិ និងឯកសារ ផ្សេងៗនោះទេ ក្រុមជាតិពន្ធុវៀតណាមមិនអាចទទួលបាននូវសិទ្ធិសេដ្ឋកិច្ចមូលដ្ឋាន នយោបាយ និងសង្គម ដោយហេតុមកពីការខ្វះឯកសារ ជាជាងដោយហេតុការរើសអើងប្រឆាំងក្រុមដោយផ្អែកលើមូលដ្ឋាននៃជាតិ ពន្ធុ។ ក្រុមចូលរួមជំហានទី២ក្នុងការស្រាវជ្រាវត្អូញត្អែថា បើគ្មានអត្តសញ្ញាបណ្ណសញ្ជាតិខ្មែរនោះទេ ពួកគេប្រឈមនឹងការជួបប្រទះគុណវិបត្តផ្នែកច្បាប់ នយោបាយ សេដ្ឋកិច្ច និងសង្គម រួមមាន លំបាកក្នុងការបម្រើការងារ ការសិក្សា តំហែទាំសុខភាព ការការពារផ្លូវច្បាប់ ការចុះសំបុត្រកំណើត និងអាពាហ៍ពិពាហ៍ មិនអាចធ្វើដំណើរ កាន់កាប់ទ្រពសម្បត្តិ ឬបើកគណនីធនាគារ និងការយកពន្ធខ្ពស់។

ទោះជាយ៉ាងណា ការតស៊ូរបស់ប្រជាជនខ្មែរក្រោមដើម្បីទទួលបានអត្តសញ្ញាណ វប្បធម៌ និងសាសនាច្បាស់លាស់កំពុងបន្តធ្វើតាមរយៈប្រវត្តិសាស្ត្ររបស់ពួកគេ។ ការរស់នៅភាគខាងត្បូងនៃប្រទេសវៀតណាម ពួកគេបន្តក្លាយជាប្រធានបទនៃការគាប់សង្កត់ និងធ្វើទុក្ខបុកម្នេញដោយរដ្ឋាភិបាលវៀតណាម។ ហេតុដូច្នេះហើយទើបធ្វើឲ្យពួកគេរត់គេចពីការរំលោភសិទ្ធិមនុស្ស និងដើម្បីស្វែងរកទីកន្លែងសុវត្ថិភាពជាងនេះក្នុងប្រទេស កម្ពុជា។ ជាទ្រឹស្តី ពួកគេត្រូវបានទទួលស្គាល់ថាជាជនជាតិខ្មែរ ជាការអនុវត្តពួកគេជួបប្រទះបញ្ហាលំបាក ជាច្រើននៅពេលដែលត្រូវទទួលបានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ ចាប់តាំងពីពួកគេមិនអាចស្វែងរកកន្លែងសុវត្ថិភាពមក ពួកគេបានបំណងធ្វើដំណើរផ្សងព្រេងដោយការលំបាក ដែលចុងក្រោយនាំឲ្យពួកគេទៅកាន់ប្រទេសថៃជាកន្លែងដែលពួកគេកំពុងព្យាយាមស្វះស្វែររកសិទ្ធិជ្រកកោន។ ក្នុងប្រទេសថៃ ពួកគេប្រឈមមុខនឹងបញ្ហាជាថ្មីជាច្រើន។ ក្រៅពីមានការត្អូញត្អែពីការរើសអើងហើយ វាកាន់តែច្បាស់ណាស់ថាខ្មែរក្រោមជាប្រជាជនជួបលំបាកភាពក្រីក្រ និងខ្វះការអប់រំ (Lyma Nguyen និងលោក Christoph Sperfeldt (២០១៥)។

ក្រោមស្ថានភាពបច្ចុប្បន្ន ការសន្យាផ្តល់សញ្ជាតិ ប៉ុន្តែមិនត្រូវបានប្រគល់ឲ្យខ្មែរក្រោមជាច្រើនដែលបានប្តេជ្ញាចិត្តអនុវត្តសេរីភាពរបស់ពួកគេ និងចាកចេញពីប្រទេសវៀតណាមដោយឆ្លងកាត់ព្រំដែនមកកម្ពុជា ដើម្បីស្វែងរកជីវិតថ្មីមួយក្នុងប្រទេសដែលមានវប្បធម៌ និងអត្តសញ្ញាណដួងព្រលឹងរបស់ពួកគេ។ ពួកគេមកកម្ពុជាដើម្បីដើម្បីស្វែងរកការទទួលបានសិទ្ធិរបស់ពួកគេថាជាប្រជាជនខ្មែរ ហើយដើម្បីរស់នៅក្រោមព្រះមហាក្សត្រខ្មែរដែលជាអធិប្បតេយ្យភាពរបស់ពួកគេ។ ទោះជាយ៉ាងណា ភាពមិនបានដឹងចំពោះមនុស្សជាច្រើន ប្រទេសកម្ពុជាបានជួបប្រទះនូវបញ្ហាថ្មីទាំងស្រុង។ ខណៈដែលរដ្ឋាភិបាលកម្ពុជាបានប្រកាសជាសាធារណៈ និងដដែលៗថាប្រជាជនខ្មែរក្រោមត្រូវបានរាប់បញ្ចូលជាជនមានសញ្ជាតិខ្មែរ និងជាជនជាតិខ្មែរនោះ តែតថភាពវិញគឺថា ខ្មែរ

ក្រោមជាច្រើនបានជួបប្រទះបញ្ហាមិនអាចយកឈ្នះបាន នៅពេលដែលពួកគេព្យាយាមទទួលបានសញ្ជាតិ តាមរយៈការដាក់ពាក្យស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដែលជាលក្ខខណ្ឌតម្រូវក្នុងការបម្រើការងារ សិក្សា សិទ្ធិដីធ្លី សុខមាលភាព និងជាទូទៅ ដើម្បីបញ្ចៀសនូវសិទ្ធិ និងអត្ថប្រយោជន៍ដែលភ្ជាប់នឹងសញ្ជាតិ/ជាតិ។ ដើម្បីត្រូវបានចាត់ទុកថាជាជនភៀសខ្លួននោះ ជននោះត្រូវតែរស់នៅក្រៅដែនដីនៃសញ្ជាតិរបស់ពួកគេ ក្រោមលក្ខខណ្ឌភ័យខ្លាចការធ្វើទុក្ខបុកម្នេញ។ ជាលទ្ធផលនៃការប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រជាជនខ្មែរក្រោមដែលចាកចេញពីប្រទេសវៀតណាម ទំនងជាមានភាពតិចតួចបំផុតក្នុងការផ្តល់សិទ្ធិជ្រកកោន និង/ឬ ឋានៈជាជនភៀសខ្លួនក្នុងប្រទេសកម្ពុជា ឬប្រទេសទី៣ (ឧទាហរណ៍ប្រទេសថៃ) លុះត្រាតែពួកគេអាចបង្ហាញពីការធ្វើទុក្ខបុកម្នេញក្នុងប្រទេសវៀតណាម និងកម្ពុជា ( មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ២០១១)។ ហេតុដូច្នេះ ជនជាតិភាគតិចនៃអន្តោប្រវេសន៍ក្នុងតំបន់ទន្លេមេគង្គបានកើតឡើងតាមរយៈច្រកផ្លូវមិនផ្លូវការ។ អន្តោប្រវេសន៍ភាគច្រើនពឹងផ្អែកលើបណ្តាញមិត្តភ័ក្រ្ត/គ្រួសារ ឬក៏ជួលសេវាអ្នករត់ការដើម្បីរៀបចំផ្លូវធ្វើដំណើរ និងជួយក្នុងការស្វែងរកការងារធ្វើ។ តាមរយៈការប៉ាន់ស្មានមួយចំនួនឃើញថា ច្រើនជាងពាក់កណ្តាលនៃជនអន្តោប្រវេសន៍ដែលបានចូលក្នុងប្រទេសថៃបានកាន់កាប់ឯកសារស្របច្បាប់ (ឯកសារបើកផ្លូវ១ថ្ងៃ ឬ៧ថ្ងៃ) ហើយក្រោយមកស្នាក់នៅលើសកំណត់ បានក្លាយជាកម្មករខុសច្បាប់ (Ana Revenga ២០០៦ )។

## ៨- <u>ការសិក្សាស្រាវជ្រាវ</u>

### ៨.១- <u>បរិបទទូទៅនៃឯកសារគតិយុត្តិ កូន និងផ្សេងៗ</u>

ជាមធ្យម ការធ្វើបទសម្ភាសន៍ម្នាក់មានរយៈពេល១០នាទី ដែលអប្បបរិមា៥នាទី និងអតិបរិមាគឺ៣៥នាទី។ ៦៥.៥%នៃអ្នកដែលត្រូវបានសម្ភាសន៍អនុញ្ញាតឲ្យថតរូបកំឡុងពេលសម្ភាសន៍។ អាយុអប្បបរិមានៃអ្នកដែលត្រូវបានសម្ភាសន៍គឺ ១៩ឆ្នាំ និងច្រើនបំផុត៨៥ឆ្នាំ ហើយអាយុមធ្យមគឺ៤៦ឆ្នាំ។ បន្ថែមពីនេះ ៨២%នៃអ្នកដែលត្រូវបានសម្ភាសន៍បានរៀបអាពាហ៍ពិពាហ៍។

<u>**ក្រាហ្វិកទី១: តួរលេខរៀបអាពាហ៍ពិពាហ៍នៃអ្នកដែលត្រូវបានសម្ភាសន៍**</u>



ក្រាហ្វិកខាងក្រោមបង្ហាញពីអ្នកត្រូវបានសម្ភាសន៍ដែលមានកូននៅសាលា។ ជាងពាក់កណ្ដាលនៃអ្នកត្រូវបានសម្ភាសន៍មានកូននៅសាលារៀន។ សាលារបស់រដ្ឋមានចំនួនភាគរយខ្ពស់បំផុតដែលកូនៗរបស់ពួកគេបានចូលសាលារៀន (៣៦%)។

សញ្ញាណនេះបង្ហាញថា សាលារដ្ឋមានលក្ខណៈពេញនិយមសម្រាប់ឪពុក-ម្ដាយ។ ទន្ទឹមនឹងនេះ ភាគរយនៃសាលាឯកជន និងសាលាសហគមន៍គឺស្ថិតនៅជិតគ្នា (១០%, ៩%)។ សាលាសហគមន៍ដំដៅដល់សាលាសហគមន៍វៀតណាម។

យោងតាមព័ត៌មានផ្ដល់ដោយអាជ្ញាធរក្នុងស្រុកបង្ហាញថា វាជាការចាប់អារម្មណ៍ណាស់ដែលគ្រប់សហគមន៍ទាំងអស់មានសាលារៀន។ គួរកត់សម្គាល់ថា ៨ក្នុងចំណោមអាជ្ញាធរក្នុងស្រុក១២បានលើកឡើងថា ១០០%នៃកុមារកម្ពុជាមានឱកាសទៅសាលារៀន។ ផ្ទុយពីការលើកឡើងខាងលើ ៦ក្នុងចំណោមអាជ្ញាធរក្នុងស្រុក១២បាននិយាយថា មានតែកុមារវៀតណាម ៣០% ឬតិចជាងនេះមានឱកាសចូលសាលារៀន។ បន្ថែមពីនេះ ៤ក្នុងចំណោមអាជ្ញាធរក្នុងស្រុក១២និយាយថា កុមារខ្មែរក្រោម២០% ឬតិចជាងនេះមានឱកាសចូលសាលារៀន។ ហេតុផលចម្បងនៃកុមារមិនបានចូលសាលារៀន រួមមាន ការខ្វះឯកសារផ្លូវច្បាប់ និងមានការរើសអើងនឹងកុមារវៀតណាម។

**<u>ក្រាហ្វិកទី២: តួរលេខកុមារទៅសាលារៀន</u>**




ក្នុងចំណោមអ្នកដែលត្រូវបានសម្ភាសន៍ទាំងអស់ ៥៩%នៃពួកគេនិយាយភាសាខ្មែរជាប្រចាំថ្ងៃ ហើយ ៤០%នៃពួកគេនិយាយភាសាវៀតណាម។ ក្រាហ្វិក៣បង្ហាញពីតួរលេខសិក្សា។ ក្នុងចំណោមនៃអ្នកដែលត្រូវបានសម្ភាសន៍ទាំងអស់ មាន៤២%ឆ្លើយថា ពួកគេមិនធ្លាប់ចូលសាលារៀនទេ ហើយ៣៤%និយាយថា ពួកគេសិក្សាបានត្រឹមបឋមសិក្សា។ បន្ថែមពីនេះ ១៣%នៃអ្នកត្រូវបានសម្ភាសន៍អាចអានបាន។ កម្រិតនៃការអប់រំបានបង្ហាញថា តិចជាង១០%នៃអ្នកត្រូវបានសម្ភាសន៍បានបញ្ចប់អនុវិទ្យាល័យ និងវិទ្យាល័យ។

តួរលេខទាំងនេះបង្ហាញថា អត្រាតួរលេខនៃអ្នកមិនចេះអក្សរមានចំនួនច្រើន ឬការអប់រំមានកម្រិត។ ត្រឹមតែ១២%នៃអ្នកទាំងនោះបានសិក្សាលើសពីបឋមសិក្សា ដែលនេះជាស្ថិតិគួរឲ្យភ្ញាក់ផ្អើលមួយ។

**ក្រាហ្វិកទី៣ តួរលេខនៃការអប់រំ**




ក្រាហ្វិកទី៤ខាងក្រោមបង្ហាញពីការមិនទទួលបានសញ្ជាតិរបស់អ្នកត្រូវបានសម្ភាសន៍។ ភាគច្រើននៃអ្នកដែលត្រូវសម្ភាសន៍គឺជនជាតិវៀតណាម (៤៦%) ខណៈដែលខ្មែរក្រោមមានចំនួន ៤៥%។ ភាគរយនៃប្រជាជនខ្មែរមានចំនួន ៧% ហើយភាគរយនៃប្រជាជនខ្មែរ-វៀតណាមគឺមិនដល់២%នោះទេ។ លើសពីនេះ ក្នុងចំណោមពួកគេ ៩៩%កាន់សាសនាព្រះពុទ្ធ ខណៈមានតែ១%ប៉ុណ្ណោះកាន់សាសនាយេស៊ូ។

**ក្រាហ្វិកទី៤ តួរលេខនៃសាសនា**



ក្រាហ្វិកទី៥បង្ហាញពីមុខរបរចម្បងរបស់អ្នកត្រូវបានសម្ភាសន៍។ ២៨%នៃអ្នកទាំងនោះគឺជាអ្នកជំនួញ ខណៈ២៦%គឺជាអ្នកនេសាទ។ ភាគរយនៃកសិករ និងកម្មករគឺមានចំនួនស្រដៀងគ្នាគឺ ១៨% និង១៥%។ អ្នកដែលនៅផ្ទះយ៉ាងហោចណាស់មាន ៤%។

**ក្រាហ្វិកទី៥ តួរលេខនៃមុខរបរ**




ក្រាហ្វិកទី៦ខាងក្រោមបង្ហាញពីបណ្តាខេត្តចម្បងដែលជនទាំងនោះកើត រស់នៅមុនពេល និងកំឡុងរបបពុលពត។ ចំណោមអ្នកទាំងនោះមាន ៥៣% គឺមានដើមកំណើតមកពីប្រទេសវៀតណាម និង៤៧% មកពីកម្ពុជា។ ភាគច្រើនកើតក្នុងខេត្តអាងយ៉ាង ២៨% (ប្រទេសវៀតណាម) ២១% ក្នុងខេត្តពោធិ៍សាត់ (ប្រទេស កម្ពុជា)។ និន្នាការនេះស្រដៀងគ្នានឹងពេលវេលាមុនពេល និងកំឡុងរបបពុលពតផងដែរ។

**ក្រាហ្វិកទី៦ តួរលេខនៃខេត្តកំណើត មុននិងកំឡុងរបបពុលពត**



ក្រាហ្វិកទី៧បង្ហាញពីភាគរយនៃអ្នកត្រូវបានសម្ភាសន៍ដែលមានកូនគ្រប់អាយុចូលសាលារៀន។ ច្រើនជាងពាក់កណ្តាលនៃពួកគេ (៥១%) ឆ្លើយថា ពួកគេមានកូនដែលគ្រប់អាយុចូលសាលារៀន។ លើសពីនេះ ១១% នៃពួកគេមិនបានឆ្លើយពាក់ព័ន្ធនឹងសំនួរនេះ។

៣៦% នៃអ្នកត្រូវបានសម្ភាសន៍សរុបដែលមានកូនគ្រប់អាយុចូលសាលារៀននិយាយថា កូនរបស់ពួកគេត្រូវបានចុះឈ្មោះឲ្យចូលសាលារៀន។ ផ្ទុយទៅវិញ ១៤% នៃអ្នកទាំងនោះនិយាយថា កូនរបស់ពួកគេមិនបានចុះឈ្មោះចូលរៀននោះទេ។ ហេតុផលចម្បងនៃការមិនបានចុះឈ្មោះចូលរៀន រួមមាន ការខ្វះឯកសារគតិយុត្តិសញ្ជាតិវៀតណាម គ្រួសារគ្មានប្រាក់កាស និងសាលារៀនស្ថិតនៅឆ្ងាយពីផ្ទះ។

**ក្រាហ្វិកទី៧ តួរលេខនៃអាយុចូលសាលារៀន និងចុះឈ្មោះចូលរៀន**




ក្រហ្វិកទី៨បង្ហាញពីអ្នកត្រូវបានសម្ភាសន៍មិនមានឯកសារផ្លូវច្បាប់ពីអាជ្ញាធរ បន្ថែមពីនេះ ក្រាហ្វិកនេះបង្ហាញពីអាត្រាភាគរយ (០%) នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងសៀវភៅគ្រួសារ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សំបុត្រកំណើត សៀវភៅស្នាក់នៅ បណ្ណបោះឆ្នោត បណ្ណអន្តោប្រវេសន៍ លិខិតបញ្ជាក់ភាពក្រីក្រ សំបុត្រអាពាហ៍ពិពាហ៍ ជាដើម។

ផ្អែកលើក្រាហ្វិកទី៨បង្ហាញថា ភាគច្រើននៃអ្នកត្រូវបានសម្ភាសន៍ដែលជាជនជាតិវៀតណាម ៣១% មានបណ្ណអន្តោប្រវេសន៍ ២៥%មានសៀវភៅស្នាក់នៅ ហើយ១៩%មានបណ្ណបោះឆ្នោត។ ទោះជាយ៉ាងណា ក្រាហ្វិករកឃើញថា ៤% នៃជនជាតិវៀតណាមមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និង៥%មានសំបុត្រ កំណើត។ ទន្ទឹមនឹងនេះ ១១% មានសៀវភៅគ្រួសារ។ ចំណែកលិខិតបញ្ជាក់ភាពក្រីក្រ និងសំបុត្រអាពាហ៍ពិពាហ៍មានតិចបំផុត គឺ៥% និង១%។

យោងតាមក្រាហ្វិកទី៨បង្ហាញថា ភាគច្រើននៃប្រជាជនខ្មែរក្រោមមានសៀវភៅគ្រួសារ (១៩%) អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (១៨%) បណ្ណបោះឆ្នោត (១៧%) សៀវភៅស្នាក់នៅ (១៦%) និងសំបុត្រកំណើត (១៥%)។ ចំណែកបណ្ណបញ្ជាក់ភាពក្រីក្រ សំបុត្រអាពាហ៍ពិពាហ៍មានចំនួនតិច គឺ៧% និង៧% ប៉ុណ្ណោះ។

ហេតុដូចនេះ ហេតុផលចម្បងដែលអ្នកទាំងនោះបានបញ្ជាក់ពីការមិនទទួលបានឯកសារទាំងនេះ គឺមានការរើសអើង (៣៤%) ពួកគេមិនដឹង (៣៣%) អត់មានប្រាក់ (២០%) ហើយអាជ្ញាធរមិនធ្វើវាឲ្យពួកគាត់ (៥%)។

បន្ថែមពីនេះ ៤៨% នៃចំនួនសរុបនៃអ្នកត្រូវបានសម្ភាសន៍បានឆ្លើយថា កូនរបស់ពួកគេមានសំបុត្រកំណើត និង២១% ឆ្លើយថា កូនពួកគេមានលិខិតបញ្ជាក់ពីគ្រូពេទ្យ។ ហេតុផលដែលកូនរបស់ពួកគេទាំងនោះ

មិនមានឯកសារគតិយុត្តិទាំងពីរនេះគឺប្រវត្តិនៃជនជាតិវៀតណាមរបស់ពួកគេ (៧៧%) ការរើសអើង (១៣%) និងអាជ្ញាធរក្នុងស្រុកមិនចេញឲ្យពួកគេ (១០%)។

តាមរយៈការប្រៀបធៀបដ៏សំខាន់នៃឯកសារគតិយុត្តិ ក្រាហ្វិកនេះបង្ហាញថា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងសំបុត្រកំណើតគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ពួកគេ។ ក្រាហ្វិកបង្ហាញថា ប្រជាជនខ្មែរក្រោមមានអត្តសញ្ញាណបណ្ណ (១៨%) និងសំបុត្រកំណើត (១៥%)។ ទោះជាយ៉ាងណាក៏ដោយ ក៏ក្រាហ្វិកបានរកឃើញថា ៤% នៃប្រជាជនវៀតណាមមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និង៥% មានសំបុត្រកំណើតដែលនេះជាភាគរយតិចតួច។

<u>**ក្រាហ្វិកទី៨ តួរលេខនៃឯកសារគតិយុត្តិដែលអ្នកត្រូវបានសម្ភាសន៍កាន់កាប់**</u>




ក្រាហ្វិកទី៩ខាងក្រោមបង្ហាញពីឯកសារគតិយុត្តិ ដែលអ្នកទាំងនោះ<u>ត្រូវការ/ចង់បានសម្រាប់លក្ខខណ្ឌរស់នៅរបស់ពួកគេ</u>។ ជាទូទៅ បើពិនិត្យលើលទ្ធផលនៃការវិភាគ ពួកគេ**ត្រូវការរាល់ឯកសារគតិយុត្តិទាំងអស់**។ ផ្អែកលើក្រាហ្វិកបង្ហាញថា សំបុត្រកំណើតមានចំនួនភាគរយខ្ពស់ជាងគេ (៩១%) ហើយ៨៨%នៃពួកគេត្រូវការអត្តសញ្ញាណបណ្ណ បន្ថែមពីនេះ ៨២% ត្រូវការសៀវភៅគ្រួសារ ទន្ទឹមនឹងនេះ លិខិតអន្តោប្រវេសន៍ស្ថិតនៅទីតាំងភាគរយតិចជាងគេបំផុត (៦១%)។ ហេតុផលសំខាន់ដែលអ្នកទាំងនោះត្រូវការឯកសារទាំងនោះព្រោះតែ វាងាយស្រួលស្វែងរកការងារ (៩៦%) ចុះឈ្មោះកូនចូលរៀន (៩៣%) និងអាជ្ញាធរត្រូវការឯកសារទាំងនេះពីពួកគេ (៨៤%)។

**ក្រាហ្វិកទី៩ តួរលេខនៃឯកសារគតិយុត្តិដែលអ្នកត្រូវបានសម្ភាសន៍ត្រូវការ**




ក្រាហ្វិកទី១០ខាងក្រោមបង្ហាញពីប្រភេទនៃអាជ្ញាធរ ឬប៉ូលីសដែលអ្នកត្រូវបានសម្ភាសន៍បានជួប។ ក្នុងចំណោមការសម្ភាសន៍ទាំងអស់ ៤៨%បានជួបជាមួយប៉ូលីសប៉ុស្តិ៍ អធិការដ្ឋាន (២៦%)។ ក្នុងការសិក្សានេះ អ្នកត្រូវបានសម្ភាសន៍បាននិយាយថា ពួកគេកម្រជួបជាមួយប៉ូលីសបរិស្ថាន ឬប៉ូលីសអន្តោប្រវេសន៍ណាស់ (១%)។

**ក្រាហ្វិកទី១០ តួរលេខនៃបានជួបអាជ្ញាធរ ឬប៉ូលីស**




ក្រាហ្វិកទី១១បង្ហាញពីតួរលេខដែលអ្នកត្រូវបានសម្ភាសន៍ត្រូវបានចាប់ខ្លួនដោយប៉ូលីស ឬក៏អត់។ មានត្រឹមតែ៦% ប៉ុណ្ណោះឆ្លើយថា ពួកគេធ្លាប់ត្រូវបានប៉ូលីសចាប់ខ្លួន ដែលតួរលេខនេះរួមបញ្ចូលទាំងប៉ូលីសអន្តោប្រវេសន៍ (៤%) និងប៉ូលីសប៉ុស្តិ៍ (២%)។ ហេតុផលចម្បងដែលត្រូវបានចាប់ខ្លួន រួមមាន ការមិនបង់កម្រៃអន្តោប្រវេសន៍ ឬសកម្មភាពនេសាទខុសច្បាប់។

ក្រាហ្វិកទី១១ តួរលេខនៃការចាប់ខ្លួន




ផ្អែកតាមក្រាហ្វិកទី១២ខាងក្រោមបានបង្ហាញ ពីការស្នើសុំរបស់ជនទាំងនោះដើម្បីទទួលបានឯកសារគតិយុត្តិស្របច្បាប់ពីអាជ្ញាធរសម្រាប់លក្ខខណ្ឌរស់នៅរបស់ពួកគេ រួមមាន អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រកំណើត និងលិខិតអន្តោប្រវេសន៍។

យើងកត់សម្គាល់ឃើញថា ៨៤% នៃអ្នកទាំងអស់នោះបានឆ្លើយថា ពួកគេបានស្នើសុំអាជ្ញាធរក្នុងស្រុក ឬប៉ូលីសដើម្បីទទួលបានឯកសារគតិយុត្តិសម្រាប់គ្រួសាររបស់ពួកគេ។ អ្វីដែលគួរកត់សម្គាល់ជាងគេគឺថា ឯកសារគតិយុត្តិសំខាន់ទាំងអស់ត្រូវបានស្នើសុំឲ្យចេញដោយអ្នកត្រូវបានសម្ភាសន៍ទាំងនេះ។ ឯកសារទាំងនោះមាន អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (៩១%) សៀវភៅគ្រួសារ (៩០%)។ ទន្ទឹមនឹងនេះ សៀវភៅស្នាក់នៅ និងសំបុត្រកំណើតមានអត្រាភាគរយដូចគ្នាគឺ (៨៦%)។ អ្វីគួរឲ្យចាប់អារម្មណ៍គឺ ៦៩% និយាយថា អាជ្ញាធរក្នុងស្រុកបានជួយចេញឯកសារគតិយុត្តិទាំងនោះដល់គ្រួសារពួកគេ។ បន្ថែមពីនេះ ៧៧% បាននិយាយថា អាជ្ញាធរយកចិត្តទុកដាក់ចំពោះពួកគេ។

ម្យ៉ាងវិញទៀត ៣១% បាននិយាយថា អាជ្ញាធរមិនបានជួយអ្វីសោះដល់ពួកគាត់។ ហេតុផលចម្បង រួមមាន ការរើសអើងដោយផ្អែកលើជាតិសាស (វៀតណាម ឬខ្មែរក្រោម) និងពួកគេគ្មានប្រាក់កាសដើម្បីយកឯកសារគតិយុត្តិទាំងនោះ។

ស្របជៀងគ្នានឹងហេតុផលខាងលើនេះ ២១% បាននិយាយថា ពួកគេបានជួបប្រទះការរើសអើងពីសំណាក់អាជ្ញាធរមូលដ្ឋាន ឬប្រជាជនខ្មែរ។ ជាតិសាសនៅតែជាកត្តាខ្ពស់បំផុតក្នុងការរើសអើង។ ពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយសាច់ញាតិ ឬអ្នកជិតខាងវិញ ៧% បានទទួលស្គាល់ថា ពួកគេមានជម្លោះជាមួយសាច់ញាតិ ឬអ្នកជិតខាងពួកគេ។ ជម្លោះជាទូទៅ រួមមាន ពាក្យសំដី ការផឹកស៊ី ឬព្រំដីជាដើម។

## ក្រាហ្វិកទី១២ តួរលេខនៃការស្នើសុំចេញឯកសារគតិយុត្តិ




នៅពេលដែលត្រូវបានសួរនាំពីផលលំបាកក្នុងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ភាពលំបាកក្នុងការធ្វើអាជីវកម្មនៅតែឈក្នុងអត្រាភាគរយខ្ពស់ជាងគេគឺ ៣១%។ ភាគរយនៃអ្នកមិនមានឯកសារគតិយុត្តិ និងអ្នកមិនមានផ្ទះ/ដីគឺស្ថិតក្នុងអត្រាស្មើគ្នា ២៥%។ បន្ថែមពីនេះ ភាគរយនៃអ្នកដែលគ្មានប្រាក់កាសដើម្បីបង់លើអន្តោប្រវេសន៍ភាព និងអ្នកដែលក្រគឺស្មើគ្នាក្នុងអត្រា ១០%។

## ក្រាហ្វិកទី១៣ តួរលេខនៃការលំបាក



ក្រាហ្វិកទី១៤បានបង្ហាញពីក្តីបារម្ភដ៏ធំធេងរបស់អ្នកទាំងនោះ។ ជាការសំខាន់ ៣៣% នៃអ្នកទាំងនោះបារម្ភពីការចាប់ខ្លួន។ អ្នកដែលមានក្តីបារម្ភលើភាពក្រីក្រ និងលើការជួបប្រទះនឹងការបង្ខំឲ្យចាកចេញគឺមានភាគរយស្រដៀងគ្នាក្នុងកម្រិត ១៧% និង១៦%។

**ក្រាហ្វិកទី១៤ តួរលេខនៃក្តីបារម្ភ**




ក្រាហ្វិកទី១៥ខាងក្រោមបង្ហាញពីការចូលរួមបោះឆ្នោត។ ៦៧% នៃអ្នកត្រូវបានសម្ភាសន៍បានបោះឆ្នោតថ្នាក់ជាតិ។ ពួកគេភាគច្រើនបានបោះឆ្នោតចំនួន ៥ដង (៣០%) និង២ដង (១៤%)។ បន្ថែមពីនេះ ភាគច្រើននៃអ្នកចូលរួមបោះឆ្នោតថ្នាក់ជាតិចុងក្រោយដែលប្រព្រឹត្តទៅក្នុងឆ្នាំ ២០១៣ (៥៣%)។

**ក្រាហ្វិកទី១៥ តួរលេខនៃការបោះឆ្នោត**



ភាគច្រើននៃអ្នកទាំងនេះមានបណ្ណបោះឆ្នោត (៥៧%) និងបានប្រើប្រាស់សម្រាប់បោះឆ្នោត។ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរត្រូវបានយកមកប្រើប្រាស់ជាញឹកញ៉ាប់បម្រើឲ្យការបោះឆ្នោត (៤០%)។ លិខិតឆ្លងដែន លិខិតអន្តោប្រវេសន៍ និងឯកសារគតិយុត្តិដ៏ទៃទៀត ត្រូវបានប្រើតិចតួចបំផុតកំឡុងពេលបោះឆ្នោត (១%)។

**<u>ក្រាហ្វិកទី១៦ តួរលេខនៃឯកសារដែលត្រូវបានប្រើសម្រាប់បោះឆ្នោត</u>**




អាជ្ញាធរមូលដ្ឋានក៏បានផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសេវាសុខភាពក្នុងសហគមន៍ពួកគេផងដែរ ដែលអាជ្ញាធរមូលដ្ឋានចំនួន៨ក្នុងចំណោមអាជ្ញាធរមូលដ្ឋាន១២បាននិយាយថា មនុស្សភាគច្រើនទៅមជ្ឈមណ្ឌលសុខភាពដើម្បីរកសេវាសុខភាព ហើយ៤ក្នុងចំណោមពួកគេនិយាយថា មនុស្សភាគច្រើនទៅរកគ្លីនិកឯកជនប្រសិនបើពួកគេត្រូវការសេវាសុខភាព។ ភាពលំបាកចម្បងបំផុតគឺថា មនុស្សម្នាក្នុងសហគមន៍ពួកគេប្រឈមនឹងបញ្ហាដូចជា ការផ្តល់សេវាសុខភាព ការខ្វះឯកសារ និងបញ្ហាប្រាក់កាស។

ចុងក្រោយ អ្នកទាំងនោះបានស្នើសុំនូវអ្វីដែលពួកគេចង់បានពាក់ព័ន្ធនឹងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ដែលត្រូវបានកត់សម្គាល់ដោយការប្រមូលទិន្នន័យរបស់យើង។ ក្រាហ្វិកទី១៧ខាងក្រោមបង្ហាញពីការសំណូមពរដែលត្រូវបានលើកឡើងដោយអ្នកទាំងនោះ។ មានភាគរយខ្ពស់បំផុតដែលបានសំណូមពរឲ្យការរស់នៅរបស់ពួកគេទីនេះបានស្របច្បាប់តាមបទបញ្ញត្តិនៃឯកសារគតិយុត្តិ (៤២%)។ សំណូមពរខ្ពស់លំដាប់ទី២គឺស្នើឲ្យមានគម្រោងចាំបាច់សម្រាប់គេហដ្ឋានមួយ និងដីមួយកន្លែងក្នុងការរស់នៅ (១៩%)។ ម្យ៉ាងវិញទៀត ចំនួនភាគរយស្នើសុំឲ្យចាប់ខ្លួន និងបង្ខំឲ្យរើលំនៅដ្ឋានទៅកាន់កន្លែងផ្សេងមានយ៉ាងហោចណាស់ (២%)។

**<u>ក្រាហ្វិកទី១៧ តួរលេខនៃសំណូមពរ</u>**




## ៨.២- <u>ច្បាប់ក្នុងស្រុកស្តីពី សញ្ជាតិ និងអន្តោប្រវេសន៍</u>

ផ្អែកតាមការវិភាគទិន្នន័យខាងលើបង្ហាញថា ជាតិពន្ធវៀតណាម និងខ្មែរក្រោមចំនួនមានឯកសារគតិយុត្តិបម្រើឲ្យការរស់នៅរបស់ពួកគេក្នុងប្រទេស ប៉ុន្តែឯកសារទាំងនោះមិនបានបញ្ជាក់ពីសញ្ជាតិរបស់ពួកគេ ទ្បើយគឺគ្រាន់តែបញ្ជាក់ពីឋានៈអន្តោប្រវេសន៍ប៉ុណ្ណោះ។ ការទទួលស្គាល់ដំណើរការអន្តោប្រវេសន៍ត្រូវបានចែងក្នុងច្បាប់ស្តីពី អន្តោប្រវេសន៍ មាត្រា១២ដែលចែងថា "ដំណើរការនៃការទទួលស្គាល់ជនបរទេសណាមួយថាជាជនបរទេសអន្តោប្រវេសន៍នោះ ត្រូវបានសម្រេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ[3]។ ហេតុដូច្នេះហើយ សម្រាប់អ្នកដែលអាចស្នើសុំសញ្ជាតិខ្មែរបានលុះត្រាតែពួកគេត្រូវបានសម្រេចដោយព្រះរាជក្រឹត្យនៃព្រះរាជាណាចក្រកម្ពុជាតាមច្បាប់ចែងថា "ការផ្តល់សញ្ជាតិខ្មែរក្រោយមានការស្នើសុំ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ[4]"។ ច្បាប់របស់កម្ពុជាស្តីពី សញ្ជាតិ បានផ្តល់សញ្ជាតិដល់កុមារណាដែលបានកើតក្នុងទឹកដីកម្ពុជា ដែល (១) កើតពីឪពុក/ម្តាយមានសញ្ជាតិខ្មែរ (២) កើតពីឪពុកម្តាយបរទេសដែល*រស់នៅស្របច្បាប់*ក្នុងប្រទេសកម្ពុជា ឬត្រូវបានរកឃើញក្នុងប្រទេសកម្ពុជា ហើយឪពុកម្តាយមិនត្រូវបានស្គាល់[5]។

ច្បាប់ស្តីពី សញ្ជាតិ បានកម្រិតតឹងរ៉ឹងចំពោះជនបរទេសអន្តោប្រវេសន៍ ប្រសិនបើពួកគេចង់ស្នើសុំសញ្ជាតិពួកគេត្រូវបំពេញតាមលក្ខខណ្ឌច្បាប់។ វាមានការប្រឈមយ៉ាងខ្លាំងចំពោះក្រុមជាតិពន្ធវៀតណាម។

[3] ច្បាប់ស្តីអន្តោប្រវេសន៍ មាត្រា ១២

[4] ច្បាប់ស្តីសញ្ជាតិឆ្នាំ១៩៩៦ មាត្រា ៥

[5] Lbid មាត្រា ៤

ក្រុមជនជាតិភាគតិចគឺជាបញ្ហាមួយអាចជិះឥទ្ធិពលដល់ក្រុមទាំងនោះ ដោយពួកគេមិនអាចទទួលសេវាកម្មក្រេឌីតពីធនាគារ ប្រព័ន្ធតុលាការ ឬដាក់ពាក្យបណ្តឹងទៅអាជ្ញាធរ សេវាសង្គម មូលដ្ឋានអប់រំជាដើម។

## ៨.៣- អនុសញ្ញាអន្តរជាតិ

*កិច្ចព្រមព្រៀងអន្តរជាតិដែលបានចុះហត្ថលេខា*

មានប្រទេសចំនួន២០ក្នុងតំបន់អាស៊ី និងអាស៊ីប៉ាស៊ីហ្វិក គឺជារដ្ឋភាគីនៃអនុសញ្ញាឆ្នាំ១៩៥១ ស្តីពី ឋានៈជនភៀសខ្លួន និងពិធីសាឆ្នាំ១៩៦៧។ ប្រទេសកម្ពុជាគឺជារដ្ឋភាគីនៃអនុសញ្ញា ហើយបានផ្តល់សច្ចាប័ន នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៩២[6]។ បន្ថែមពីនេះ កម្ពុជាក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពី សិទ្ធិកុមារផងដែរ។

*កិច្ចព្រមព្រៀងអន្តរជាតិដែលបានចុះហត្ថលេខា*

មានប្រទេសជាច្រើនលើពិភពលោកបានផ្តល់សច្ចាប័នលើអនុសញ្ញាឆ្នាំ១៩៥៤ ស្តីពី ជនជាតិភាគតិច និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពី ការកាត់បន្ថយជនជាតិភាគតិច[7]។ ប្រទេសកម្ពុជាមិនបានផ្តល់សច្ចាប័នលើអនុសញ្ញាខាងលើនេះទេ។

## ៩- សន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការវិភាគខាងលើបង្ហាញថា មានមនុស្សចំនួន៣៧៤នាក់ត្រូវបានសម្ភាសន៍ ដែលត្រូវបានសង្ខេបដូចខាងក្រោម៖

១- សាលារដ្ឋគឺមានការពេញនិយមចូលចិត្តចំពោះឪពុកម្តាយនៅសហគមន៍ ក្នុងការបញ្ជូនកូនរបស់ពួកគេទៅសាលារៀន។

២- ជាង២/៣នៃអ្នកត្រូវបានសម្ភាសន៍មិនបានសិក្សា ឬសិក្សាត្រឹមក្រោមអនុវិទ្យាល័យ។

៣- ជនជាតិភាគតិចមានមុខរបរខុសៗគ្នា ដែលភាគច្រើនគឺជាអ្នកជំនួញ អ្នកនេសាទ កសិករ និង កម្មករ។

៤- ៣២% នៃជនជាតិវៀតណាមមានលិខិតអន្តោប្រវេសន៍ ២៥% មានសៀវភៅស្នាក់នៅ និង១៩%មានបណ្ណបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ ក្រាហ្វិកបានរកឃើញថា ៤% នៃជនជាតិវៀតណាមមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និង៥% មានសំបុត្រកំណើត។ ទន្ទឹមនឹងនេះ ១១% មានសៀវភៅគ្រួសារ។ ចំណែកឯប្រជាជនខ្មែរក្រោមដែលមានសៀវភៅគ្រួសារគឺ (១៩%) អត្តសញ្ញាណបណ្ណ (១៨%) បណ្ណបោះឆ្នោត (១៧%) សៀវភៅស្នាក់នៅ (១៦%) និងសំបុត្រកំណើត(១៥%)។ ដូច្នេះ មានហេតុផលចម្បងដែលពួកគេនិយាយពីការមិនទទួលបានឯកសារទាំងនេះមានដូចជាការរើសអើង (៣៤%) ពួកគេមិនបានដឹង (៣៣%) គ្មានប្រាក់កាស (២០%) និងអាជ្ញាធរមូលដ្ឋានមិនចេញវាឲ្យពួកគេ (៥%)។ តាមរយៈការប្រៀបធៀបឯកសារគតិយុត្តិរកឃើញថា ការមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងសំបុត្រកំណើតគឺមានសារៈសំខាន់បំផុតសម្រាប់ពួកគេ ខណៈដែលប្រជាជនខ្មែរក្រោមមានអត្តសញ្ញាណបណ្ណ (១៨%) និងសំបុត្រកំណើត (១៥%) ទោះជា

[6] ការិយាល័យគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក បញ្ជីរដ្ឋភាគីនៃសន្ធិសញ្ញាក្នុងតំបន់អាស៊ី/ប៉ាស៊ីហ្វិក ចុះថ្ងៃទី កញ្ញា ឆ្នាំ ២០១៤ ទំព័រទី ៧

[7] ការិយាល័យគណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក បញ្ជីរដ្ឋភាគីនៃសន្ធិសញ្ញាក្នុងតំបន់អាស៊ី/ប៉ាស៊ីហ្វិក ចុះថ្ងៃទី កញ្ញា ឆ្នាំ ២០១៤ ទំព័រទី ៧

យ៉ាងណាយើងបានរកឃើញថា ៤% នៃជនជាតិវៀតណាមមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និង៥% មានសំបុត្រកំណើត។

៥- ជិតពាក់កណ្តាលនៃអ្នកត្រូវបានសម្ភាសន៍និយាយថា កូនរបស់ពួកគេមានសំបុត្រកំណើត ហើយ ១/៥ បាននិយាយថា កូនរបស់ពួកគេមានសំបុត្រពេទ្យបញ្ជាក់។ ហេតុផលដែលកូនរបស់ពួកគេមិនទទួលបានឯកសារគតិយុត្តិសំខាន់ទាំងពីរនេះគឺព្រោះតែ ប្រវត្តិជាជនជាតិវៀតណាមរបស់ពួកគេ (៧៧%) ការរើសអើង (១៣%) និងអាជ្ញាធរមូលដ្ឋានមិនចេញឲ្យពួកគេ (១០%)។

៦- មានភាគរយខ្ពស់បំផុតនៃអ្នកទាំងនោះ (៩១%) ត្រូវការសំបុត្រកំណើត ៨៨% ត្រូវការអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ បន្ថែមពីនេះ ៨២%ត្រូវការសៀវភៅគ្រួសារ ហើយទន្ទឹមនឹងនេះ លិខិតអន្តោប្រវេសន៍គឺស្ថិតនៅអត្រាទាបជាងគេ (៦១%)។ ហេតុផលដែលពួកគេត្រូវការឯកសារទាំងនេះរួមមាន៖ ងាយស្រួលរកការងារ (៩៦%) ចុះឈ្មោះកូនទៅសាលារៀន (៩៣%) និងអាជ្ញា ធរមូលដ្ឋានត្រូវការឯកសារទាំងនេះពីពួកគេ (៨៤%)។

៧- ជាងពាក់កណ្តាលនៃពួកគេបានជួបប៉ូលីសប៉ុស្តិ៍ព្រោះប៉ូលីសប្រភេទនេះមានទីតាំងក្នុង ឬក្បែរសហគមន៍ពួកគេ។ ជាងនេះទៅទៀត តិចជាង១០% និយាយថា ពួកគេត្រូវបានប៉ូលីសអន្តោ ប្រវេសន៍ ឬប៉ូលីសប៉ុស្តិ៍ចាប់ខ្លួន។ ហេតុដែលដែលប៉ូលីសចាប់ខ្លួនរួមមាន ការមិនបង់កម្រៃអន្តោប្រវេសន៍ ឬនេសាទខុសច្បាប់។

៨- ផ្អែកតាម<u>សំណូមពររបស់អ្នកត្រូវបានសម្ភាសន៍ទាំងនោះ បាន</u>ស្នើសុំអាជ្ញាធរមូលដ្ឋានចេញលិខិតឯកសារគតិយុត្តិដល់ពួកគេសម្រាប់រស់នៅ រួមមាន អត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រកំណើត និងលិខិតអន្តោប្រវេសន៍។ ៩១% បានស្នើសុំអត្តសញ្ញាណបណ្ណ ៩០% ស្នើសុំសៀវភៅគ្រួសារ។ ទន្ទឹមនឹងនេះ បណ្ណរស់នៅ និងសំបុត្រកំណើតមានអាត្រាភាគរយដូចគ្នាគឺ (៨៦%)។

៩- ពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយសាច់ញាតិ ឬអ្នកជិតខាងវិញនោះ តិចជាង១០% នៃពួកគេទទួលស្គាល់ថា ពួកគេមានជម្លោះជាមួយសាច់ញាតិ ឬអ្នកជិតខាងពួកគេ។ ជម្លោះភាគច្រើនមានដូចជាពាក្យសំដី ការផឹកស៊ី ឬព្រំដី។ មានន័យថា ជម្លោះកើតឡើងដោយសារសកម្មភាពប្រចាំថ្ងៃ មិនមែនកើតមកពីការរើសអើងពូជសាសន៍នោះទេ។

១០- ពិបាកធ្វើអាជីវកម្ម គ្មានឯកសារគតិយុត្តិ និងគ្មានគេហដ្ឋាន/ដីរស់នៅ បានឈរក្នុងលំដាប់ខ្ពស់បំផុត (ក្តីលំបាកទាំង៣នេះស្ថិតក្នុងកម្រិត ៨០%)។

១១- ជាងនេះទៅទៀត ច្រើនជាងពាក់កណ្តាលនៃពួកគេបារម្ភពីការចាំខ្លួន ភាពក្រីក្រ និងការបង្ខំឲ្យចាកចេញក៏ជាអ្វីដែលត្រូវបានលើកឡើងផងដែរ។

១២- ប្រហែល២/៣នៃពួកគេបាននិយាយថា ពួកគេមិនធ្លាប់ថ្នាក់ជាតិនោះទេ។ ៣០% ក្នុងចំណោមនៃអ្នកត្រូវបានសម្ភាសន៍បានបោះឆ្នោត៥ដង។ បន្ថែមពីនេះ ភាគច្រើនពួកគេបានទៅបោះឆ្នោតនៅក្នុងកំឡុងពេលបោះឆ្នោតចុងក្រោយឆ្នាំ ២០១៣។ ឯកសារគតិយុត្តិសំខាន់បម្រើឲ្យការបោះឆ្នោតរួមមាន បណ្ណបោះឆ្នោត និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

១៣- ពួកគេបានសំណូមពរសំខាន់៣ដែលរួមមាន ការអនុញ្ញាតឲ្យរស់នៅទីនេះស្របច្បាប់ដោយផ្តល់ឯកសារគតិយុត្តិ ត្រូវការផ្ទះ/ដី សម្រាប់រស់នៅ និងសាងសង់/ជួសជុលសាលារៀនសម្រាប់ឲ្យកូនពួកគេសិក្សារៀនសូត្រ។

## ១០- អនុសាសន៍

អនុសាសន៍ចំពោះរដ្ឋាភិបាល អង្គការការពារសិទ្ធិជនជាតិភាគតិច និងសង្គមស៊ីវិល មានដូចខាង ក្រោម ៖

### *១០.១- អនុសាសន៍ចំពោះរដ្ឋាភិបាល*

១. រដ្ឋាភិបាលគួរសាងសង់សាលារៀនឲ្យបានច្រើនសម្រាប់កុមារ ជាពិសេស សាលាមត្តេយ្យ និងបឋមសិក្សា (ទាំងការអប់រំផ្លូវការ និងក្រៅផ្លូវការ)។ សាលារៀនគួរតែត្រូវបានទទួលស្គាល់ដោយរដ្ឋ ពីព្រោះ វាជាការនិយមចូលចិត្ត និងមានទំនុកចិត្តក្នុងចំណោមឪពុកម្តាយរបស់ពួកគេ។ ទីតាំងសាលាគួរស្ថិតនៅកន្លែងដែលពួកគេអាចទទួលយកបាន។ លើសពីនេះ ភាគីពាក់ព័ន្ធទាំងនេះគួរផ្តល់សម្ភារៈសាលាដូចជា សៀវភៅ ខ្មៅដៃ ប៊ិច កាបូបសម្រាប់កូនសិស្សដើម្បីលើកទឹកចិត្តពួកគេបន្តការសិក្សា។

### *១០.២- អនុសាសន៍ចំពោះអង្គការការពារសិទ្ធិជនជាតិភាគតិច និងសង្គមស៊ីវិល*

២. អង្គការការពារសិទ្ធិជនជាតិភាគតិច និងដៃគូសង្គមស៊ីវិលពាក់ព័ន្ធគួរបង្រៀនក្រុមជនជាតិភាគតិចទាំងនោះពីរបៀបអាន និងសរសេរលិខិតតាមពេលវេលាសមស្របរបស់ពួកគេ។ បន្ទាប់មក ពួកគេគួរតែត្រូវបានបណ្តុះបណ្តាលបន្ថែមទៀតអំពីការចាប់ផ្តើមធ្វើអាជីវកម្ម ឬអប់រំហិរញ្ញវត្ថុពីព្រោះ ជនទាំងនោះមានចំណេះដឹងតិចតួច ការធ្វើអាជីវកម្មតាមរដូវ និងលើកអំពីផលលំបាកក្នុងការធ្វើអាជីវកម្ម។

៣. អង្គការការពារសិទ្ធិជនជាតិភាគតិចគួរធ្វើការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន និងប៉ូលីសអន្តោប្រវេសន៍ក្នុងការចេញឯកសារគតិយុត្តិដល់ក្រុមជនជាតិភាគតិចទាំងនោះ ដែលមានដូចជាលិខិតអន្តោប្រវេសន៍ សៀវភៅគ្រួសារ សំបុត្រកំណើត និងសៀវភៅស្នាក់នៅចំពោះអ្នកដែលបានរស់នៅច្រើនជាង៧ឆ្នាំ[8] ដើម្បីអាចឲ្យពួកគេងាយស្រួលរកការងារ ងាយស្រួលបញ្ជូនកូនទៅសាលារៀន និងប៉ូលីសមិនចាប់ខ្លួនពួកគេ។

៤. អង្គការការពារសិទ្ធិជនជាតិភាគតិចគួរធ្វើការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីស្វែងរក ទិញដីសមរម្យរួចផ្តល់ជូនពួកគេដើម្បីឲ្យជនទាំងនោះសាងសង់លំនៅដ្ឋានរបស់ពួកគេ ជៀសវាងការបង្ខំឲ្យចាកចេញពីកន្លែងដែលពួកគេមិនចង់រស់នៅ។ ពួកគេមិនហ៊ានតវ៉ាដោយហេតុថាពួកគេគិតថាការរស់នៅរបស់ពួកគេមិនស្របច្បាប់។

៥. អង្គការការពារសិទ្ធិជនជាតិភាគតិចគួរអនុវត្តការរៀបចំផែនទីដល់ក្រុមជាតិពន្ធុវៀតណាម និងខ្មែរក្រោមដើម្បីកំណត់ពីខេត្តទាំង៣ដែលត្រូវបានស្រាវជ្រាវ។

៦. អង្គការការពារសិទ្ធិជនជាតិភាគតិច ត្រូវបានលើកទឹកចិត្តបង្កើនការភ្ជាប់ទំនាក់ទំនងរបស់ខ្លួនជាមួយអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិលលើការកំណត់អត្តសញ្ញាណជនជាតិភាគតិច ជាពិសេស បន្តកិច្ចខិតខំប្រឹងប្រែងលើកកំពស់វិធានសាមគ្គីតាមអត្ថន័យនៃជនជាតិភាគតិច ដោយផ្អែកលើច្បាប់អន្តរជាតិ។

៧. ក្នុងការអនុវត្តការកំណត់ឋានៈជនភៀសខ្លួន (ជនភៀសខ្លួនខ្មែរក្រោម) បុគ្គលិករបស់អង្គការការពារសិទ្ធិជនជាតិភាគតិចគួរកំណត់អត្តសញ្ញាណផងដែរនូវជនទាំងនោះ ឬជនស្ថិតក្នុងហានិភ័យ។

[8] ព្រះរាជក្រមនៃច្បាប់ស្តីពីសញ្ជាតិកម្ពុជា មាត្រា ៨ និងមាត្រា៩

៨. អង្គការការពារសិទ្ធិជនជាតិភាគតិច គួរស្វែងរកោល់ឱកាសដើម្បីពង្រឹងសហប្រតិបត្តិការជាមួយដៃគូសង្គមស៊ីវិល ធ្វើសកម្មភាពទាក់ទងនឹងការប្រមូលព័ត៌មាន/ទិន្នន័យនៃជនភាគតិចទាំងនោះ។

៩. អង្គការការពារសិទ្ធិជនជាតិភាគតិច គួរតែធ្វើកិច្ចប្រតិបត្តិការជាមួយរដ្ឋាភិបាលដើម្បីរកឲ្យឃើញ តួរលេខនៃជនជាតិភាគតិចក្នុងប្រទេសកម្ពុជាដោយយន្តការក្នុងស្រុក។

# ឯកសារយោង

អនុសញ្ញា (១៩៥៤) *អត្ថបទនៃអនុសញ្ញាពាក់ព័ន្ធនឹងឋានៈនៃជនជាតិភាគតិច-១៩៥៤។* កែសម្រួលឡើងវិញនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៦ ពី
http://www.unhcr.org/protection/statelessness/3bbb25729/convention-relating-status-stateless-persons.html

អនុសញ្ញា (១៩៦១) *អត្ថបទនៃអនុសញ្ញាពាក់ព័ន្ធនឹងការកាត់បន្ថយជនជាតិភាគតិច-១៩៦១។* កែសម្រួល ឡើងវិញនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៦ ពី
http://www.unhcr.org/protection/statelessness/3bbb286d8/convention-reduction-statelessness.html

គណៈកម្មាធិការជាន់ខ្ពស់អង្គការសហប្រជាតិទទួលបន្ទុកជនភៀសខ្លួន (២០១៤) ផែនការសកម្មភាពសាកល ក្នុងការបញ្ចប់ជនជាតិភាគតិចៈ ២០១៤-២០២៤។ កែសម្រួល ឡើងវិញនៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៦ ពី
http://www.refworld.org/docid/545b47d64.html

លោក Lyma Nguyen និងលោក Christoph Sperfeldt (២០១២)។ *នាវាគ្មានយុថ្កាៈ គឺជារបាយការណ៍ស្តីពី ឋានៈគតិយុត្តិនៃក្រុមជាតិពន្ធវៀតណាមក្នុងប្រទេសកម្ពុជា ក្រោមច្បាប់ក្នុងស្រុក និងអន្តរជាតិស្តីពីសញ្ជាតិ និងជនជាតិភាគតិច។* ភ្នំពេញ ប្រទេសកម្ពុជា សេវាជនភៀសខ្លួន។ កែសម្រួល ឡើងវិញនៅថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០១៦ ពី
http://jrscambodia.org/publication/boat_without_anchors_jrs.pdf

កម្មវិធីអន្តរភ្នាក់ងារអង្គការសហប្រជាតិស្តីពី ការជួញដូរមនុស្ស (២០០៨)។ *ព័ត៌មានយុទ្ធសាស្ត្រឆ្លើយតបនឹង បណ្តាញៈ ទិន្នន័យជួញដូរមនុស្ស។* កែសម្រួល ឡើងវិញនៅថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៦ ពី
http://www.no-trafficking.org/reports_docs/vietnam/vietnam_datasheet_eng.pdf

នាយកដ្ឋានកុងស៊ុលនៃក្រសួងការបរទេសវៀតណាម (២០១២)។ ពិនិត្យអន្តោប្រវេសន៍វៀតណាមនៅបរទេស។ ទីក្រុងហាណូយ វៀតណាមៈ អ្នកនិពន្ធ កែសម្រួល ឡើងវិញនៅថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៦ ពី
https://eeas.europa.eu/delegations/vietnam/documents/eu_vietnam/vn_migration_abroad_en.pdf

លោក Ana Revenga (២០០៦)។ *បំលាស់ទីពលកម្មក្នុងមហាអនុតំបន់ទន្លេមេគង្គ។ របាយការជំហានទី១។ ធនាគារពិភពលោក។* កែសម្រួល ឡើងវិញនៅថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០១៦ ពី
http://siteresources.worldbank.org/INTTHAILAND/Resources/333200-1089943634036/475256-1151398858396/LM_in_GMSs_Nov06.pdf

វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយអភិវឌ្ឍនឯករាជ្យឈានមុខរបស់កម្ពុជា (២០០៩)។ *ចំណាយ និងអត្ថប្រយោជន៍នៃការបំលាស់ទីពលកម្មក្នុងមហាអនុតំបន់ទន្លេមេគង្គ។ ករណីយសិក្សាក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។* ភ្នំពេញ ប្រទេសកម្ពុជា អ្នកនិពន្ធៈ កែសម្រួល ឡើងវិញនៅថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៦ ពី
http://www.cdri.org.kh/webdata/download/wp/wp45e.pdf

លោក Laura Marcia Kirchner (២០១៥)។ *ការរស់នៅជារឹមទំព័រ: ស្តីពី ឋាន: និងការរើបឈេនៃក្រុមជនជាតិភាគតិច ក្នុងប្រទេសកម្ពុជា។* ភ្នំពេញ ប្រទេសកម្ពុជា: Heinrich Boll Stiftung។ កែសម្រួល ឡើងវិញនៅថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៦ ពី
http://kh.boell.org/sites/default/files/hbs_living-on-the-margins_a5_3_rz-online-with-publishing-date.pdf

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (២០១១)។ ការសន្យាក្លែងក្លាយ: ការរុករកសិទ្ធិសញ្ជាតិនៃខ្មែរក្រោមក្នុងប្រទេសកម្ពុជា។ ភ្នំពេញ ប្រទេសកម្ពុជា: អ្នកនិពន្ធ។ កែសម្រួល ឡើងវិញនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦ ពី
http://cchrcambodia.org/admin/media/report/report/english/CCHR_Report_Exec_Summary_and_Recommendations%20_False_Promises_Exploring_the_Citizenship_Rights_of_the_Khmer_Krom_in_Cambodia_en.pdf

លោក Nicolas Lainez (២០១១)។ កុមារ និងព្រហ្មចារីយ៍ភាព: *ជាតិពន្ធុសាស្ត្រនៃជនជាតិវៀតណាមនៅ ភ្នំពេញ។* ទីក្រុងហូជីមិញ វៀតណាម: ប្រឆាំងការជួញដូរនៅវៀតណាម។ កែសម្រួល ឡើងវិញនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦ ពី
ftp://ftp2.allianceantitrafic.org/alliancea/Research_reports/AAT_ResearchReport_02-TransactedKinship.pdf

១. ព្រះរាជក្រមនៃច្បាប់ស្តីសញ្ជាតិខ្មែរ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៩៩ មាត្រា៨ និងមាត្រា៩
២. <http://www.nis.gov.kh> (accessed November 11, 2015)
៣. http://www.unhcr.orgការិយាល័យគណ:កម្មាធិការជាន់ខ្ពស់អង្គការសហប្រជាតិទទួលបន្ទុកជនភៀសខ្លួនក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក: បញ្ជីរដ្ឋភាគីនៃអនុសញ្ញាក្នុងតំបន់អាស៊ី/ប៉ាស៊ីហ្វិក ចុះខែ កញ្ញា ឆ្នាំ ២០១៤ ទំព័រទី២)
៤. ការិយាល័យគណ:កម្មាធិការជាន់ខ្ពស់អង្គការសហប្រជាតិទទួលបន្ទុកជនភៀសខ្លួនក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក: បញ្ជីរដ្ឋភាគីនៃអនុសញ្ញាក្នុងតំបន់អាស៊ី/ប៉ាស៊ីហ្វិក ចុះខែ កញ្ញា ឆ្នាំ២០១៤ ទំព័រទី៧)

## បញ្ជីក្រាហ្វិក


ក្រាហ្វិកទី១ : តួរលេខរៀបអាពាហ៍ពិពាហ៍នៃអ្នកដែលត្រូវបានសម្ភាសន៍

ក្រាហ្វិកទី២ : តួរលេខកុមារទៅសាលារៀន

ក្រាហ្វិកទី៣ : តួរលេខនៃការអប់រំ

ក្រាហ្វិកទី៤ : តួរលេខនៃសាសនា

ក្រាហ្វិកទី៥ : តួរលេខនៃមុខរបរ

ក្រាហ្វិកទី៦ : តួរលេខនៃខេត្តកំណើត មុននិងកំឡុងរបបពុលពត

ក្រាហ្វិកទី៧ : តួរលេខនៃអាយុចូលសាលារៀន និងចុះឈ្មោះចូលរៀន

ក្រាហ្វិកទី៨ : តួរលេខនៃឯកសារគតិយុត្តិដែលអ្នកត្រូវបានសម្ភាសន៍កាន់កាប់

ក្រាហ្វិកទី៩ : តួរលេខនៃឯកសារគតិយុត្តិដែលអ្នកត្រូវបានសម្ភាសន៍ត្រូវការ

ក្រាហ្វិកទី១០: តួរលេខនៃបានជួបអាជ្ញាធរ ឬប៉ូលីស

ក្រាហ្វិកទី១១: តួរលេខនៃការចាប់ខ្លួន

ក្រាហ្វិកទី១២: តួរលេខនៃការស្នើសុំចេញឯកសារគតិយុត្តិ

ក្រាហ្វិកទី១៣: តួរលេខនៃការលំបាក

ក្រាហ្វិកទី១៤: តួរលេខនៃក្តីបារម្ភ

ក្រាហ្វិកទី១៥: តួរលេខនៃការបោះឆ្នោត

ក្រាហ្វិកទី១៦: តួរលេខនៃឯកសារដែលត្រូវបានប្រើសម្រាប់បោះឆ្នោត

ក្រាហ្វិកទី១៧: តួរលេខនៃសំណូមពរ